Buddhist Institute LIBRARY

# សំខារប្រិយាយ

រៀបរៀងដោយ

សម្តេច

ព្រះធម្មលិខិត **លាស់ ឡាយ** វត្តសន្សំកុសល

ព.ស ២៥៤០

គ.ស. ១៩៩៧

២៨៣.
២៩

# ស្កាំដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្កាំដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្កាំដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

២៤៣.២៩



ភិក្ខុ **ពេន តារម្យ**

មានសទ្ធាជ្រះថ្លាបានបោះពុម្ពសៀវភៅនេះចែកជូន ជាធម្មទានក្នុងឱកាសបុណ្យខួបចំពោះវិញ្ញាណក្ខន្ធ ញោមប្រុសនាម **ពេន តឿង** ដែលធ្វើមរណកាល ទៅកាន់បរលោកក្នុងជន្មាយុ ៥៣ ឆ្នាំ ។

ខ្ញុំព្រះករុណាអាត្មាភាពសូមឧទ្ទិសភាគផលកុសលនៃធម្មទាននេះ សូមចំរើនសិរីសួស្តីជ័យមង្គល វិបុលសុខគ្រប់យ៉ាង ដល់លោកអ្នកសិក្សានិងលោកអ្នកស្តាប់នូវធម៌នេះអស់កាលជាយូរអង្វែងទៅហោង ។

សូមឧទ្ទិសភាគផលកុសលនៃធម្មទាននេះ ជូនដល់បុព្វការីជនមានមាតានាម **ធី សំ** ដែលមាន ជន្មាយុនៅឡើយ សូមប្រកបដោយពុទ្ធពរ៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈជានិច្ចនិរន្តរ៍តរៀងទៅ ។ ជាពិសេសចំពោះបីតានាម

LIBRARY BUDDHIST INSTITUTE

៣៦៣៩/៩៧

**ពេន សឿន** ដែលទើបនឹងអនិច្ចកម្មទៅកាន់បរលោក ថ្ងៃ១១កើតខែមិគសិរព.ស២៥៣៧ ត្រូវនិងថ្ងៃសុក្រ ទី២៤ខែធ្នូឆ្នាំ១៩៩៣ ព្រមទាំងញាតិកាទាំង៧សន្តាន សូមលោកបានទទួលនូវចំណែកភាគផលមហាកុសលនៃធម្មទាននេះតាមសេចក្ដីប្រាថ្នាកុំបីអាក់ខានឡើយ ។ ដោយតេជានុភាពនៃធម្មទាននិងកតញ្ញូតាធម៌នេះ សូមឱ្យខ្ញុំព្រះករុណាអាត្មាភាពអស់ទៅនូវអាសវក្កិលេសពីខន្ធសន្តានកុំបីមានសេសសល់ឡើយ ។ ខ្ញុំព្រះករុណា អាត្មាភាពនៅអន្ទោលទៅមកក្នុងភពតូច.ធំនៅឡើយ សូមឱ្យខ្ញុំព្រះករុណាអាត្មាភាព មានបញ្ញាជាសម្មាទិដ្ឋិ គ្រប់ៗជាតិ ទៅហោង ។

ភិក្ខុ ពេន ភារម្យ

វត្តឧត្តរាវតី ឃុំឫស្សីកែវខណ្ឌឫស្សីកែវ

ក្រុងភ្នំពេញ

# ឧប្បត្តិហេតុ

សៀវភៅ (សំខារប្បរិយាយ)ដែលព្រះតេជគុណ អស់លោកអ្នកកំពុងកាន់អាននេះកើតជាថ្មីឡើងវិញ ដោយខ្ញុំព្រះករុណាភិក្ខុ **ពេន នារះម្ស** ជាសិស្សបំរើ ផ្ទាល់របស់សម្ដេចព្រះគ្រូធម្មលិខិត លាស់ឡាយ បានចូលសុំការអនុញ្ញាតពីសម្ដេច ដើម្បីជ្រើសរើសរកធម៌ណាមួយដើម្បីបោះពុម្ពចែកជាធម្មទាន ដល់ពុទ្ធបរិស័ទទូទៅទុកជាគ្រឿងពិចារណាអប់រំដល់ខ្លួនយើងគ្រប់ៗគ្នា សម្ដេចព្រះធម្មលិខិតបានប្រទាន(សំខារប្បរិយាយ)មួយក្បាលនេះឱ្យយកមកបោះពុម្ពចែកជាធម្មទានដល់ពុទ្ធ បរិស័ទទូទៅ ដើម្បីបានពិចារណាយល់ដឹងនូវ(សំខារប្បរិយាយ )នេះ ។

ខ្ញុំព្រះករុណាអាត្មាភាពមានសេចក្ដីត្រេកអរយ៉ាង ខ្លាំងចំពោះសន្ដានព្រះទ័យរបស់សម្ដេចព្រះគ្រូធម្មលិខិត ដែលបានប្រទាន(សំខារប្បរិយា) នេះឱ្យបោះពុម្ពចែកផ្សាយជាធម្មទានសូមប្រគេនមហាកុសលនេះចំពោះ សម្ដេចធម្មលិខិត **លាស់ ឡាយ** សូមសម្ដេចមាន ព្រះសុខភាពល្អបរិបូណ៌ ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណភ្លឺថ្លាដើម្បីបានគង់នៅដឹកនាំព្រះពុទ្ធសាសនាចំរើនរុងរឿងតទៅអនាគត។ នៅទីបំផុតនេះសូមអស់លោក អ្នកដែលជាសប្បុរសទាំងឡាយ ដែលមានសទ្ធាបាន សិក្សាធម៌(សំខារប្បរិយាយ)នេះ ហើយសូមតាំងមេត្តាចិត្តផ្សាយចំណែកបុណ្យនេះជូនចំពោះញោមប្រុស

ខ្ញុំព្រះករុណាអាត្មាភាពផង ដែលគាត់អញ្ជើញទៅកាន់បរលោកហើយ នោះតាមកំលាំងសទ្ធាតិចច្រើន ។

ព្រោះថាការតាំងចិត្តផ្សាយបុណ្យនេះ ប្រៀបដូចជាអ្នកបង្រៀនលេខ, អក្សរ, ធម៌អាថ៌ ។ល ។ ដល់អ្នកទាំងពួង។ វិជ្ជាទាំងនោះមិនមែនរបូតចេញពី មាត់ឬពីសន្តានចិត្តរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញរឹងរិត តែចំណេះវិជ្ជាចាំស្ទាត់ទៅវឡើង,យ៉ាងណាមិញការតាំងចិត្តមេត្តាផ្សាយបុណ្យក៏ដូច្នោះដែរ ។

ភិក្ខុ **ពេន** **តារម្យ**

ព.ស ២៥៤០

ថ្ងៃទី ៣០ ខែ មីនា

គ.ស ១៩៩៧

# កថាមគ្គ

អត្ថបទនេះខ្ញុំបានដកស្រង់ដោយប្រែសង្ខេបពីគម្ពីរអភិធម្ម ត្រង់បដិច្ចសមុប្បាទវិភង្គវណ្ណនានិងវិសុទ្ធិមគ្គតាំងពី ព.ស.២៥១០ មកម្ល៉េះខ្ញុំមិនបានប្រែឱ្យហូរហែ តាមលំដាប់លំដោយប្រយោគបាលីនោះទេ ដោយគ្រែងវាពិស្តាររពេកពិបាកចាត់ការបោះពុម្ព. ប្រែយកតែចំណុចណាដែលសមតាមមាតិកាធម៌និងមានប្រយោជន៍ ហើយអត្ថបទនេះខ្ញុំឱ្យឈ្មោះថា **(សំខារបរិយាយ)** ។

លុះមកដល់ ព.ស.២៥១៧ លោក **ទេព អ៊ុន** និងអ្នកស្រី **ញ៉ែម តាន** បានមកសុំអត្ថបទនេះយកទៅបោះពុម្ព ចែកជាធម្មទាន តាមវត្ថុបំណងនិងសេចក្តីជ្រះថ្លារបស់លោក ។

អាត្មាជាម្ចាស់អត្ថបទក៏ជូននូវអត្ថបទនេះដល់លោកទេព អ៊ុន និងអ្នកស្រីដោយសោមនស្សជាទីបំផុត ហើយជាអ្នកចូលដៃក្នុងការបោះពុម្ពចែកជាធម្មទាននេះផងដែរ ។

សៀវភៅ **(សំខារបរិយាយ)** នេះភាគច្រើនពុំមែនជារបៀបស្រាវជ្រាវឬរឿងបុគ្គលាធិដ្ឋានទេ តែវាជារបៀបធម្មាធិដ្ឋានសុទ្ធ គោលដើមនិយាយពី.សំខារពីរគឺ:

**១ អវិជ្ជាបច្ចយាសំខារ ២ សំខារសរឡូន អាគតសំខារ** ។

**អវិជ្ជាបច្ចយា សំខារមាន ៦ គឺ:**

១. បុញ្ញាភិសំខារ ទំព័រ ៧
២. អបុញ្ញាភិសំខារ ៖ ១០
៣. អានេញ្ជាភិសំខារ ៖ ១៦
៤. កាយសំខារ ៖ ១៨
៥. វចីសំខារ ៖ ១៩
៦. ចិត្តសំខារ ៖ ២០

**សំខារសង្ខេប អាគតសំខារមាន៤គឺ:**

១. សំខតសំខារ ទំព័រ ២២
២. អភិសំខតសំខារ ៖ ២៦
៣. អភិសំខរណកសំខារ ៖ ៣៦
៤. បយោគាភិសំខារ ៖ ៤៣

ទីបំផុតខ្ញុំ សូមទាញអារម្មណ៍លោកអ្នកអានថា: ការរចនានូវអ្វីមួយគង់តែមានវិបត្តិ ឬផ្គាំផ្គងខ្វះៗមិនខាន បើមានដូចនេះមែន សូមវិញ្ញូជនទាំងឡាយកុំមើលបំណាំឱ្យសោះព្រោះការវិបត្តិ ឬផ្គាំផ្គងនេះវាកើតដោយក្តីភាន់ច្រឡំក៏មាន ដោយការប្រហែសធ្វេសក៏មាន និងដោយពិនិត្យយ៉ាងប្រយត្ន័ប្រយែងដែរតែយល់មិនដល់ក៏មាន ។

ដោយអានុភាពនៃធម្មទានានិសង្សនេះសូមលោក **ទេព អ៊ុន** និងក្រុមគ្រួសារបានទទួលនូវផលសម្រេចសមតាមសេចក្តីប្រាថ្នា ក្នុងសាសនាព្រះអរិយមេត្តេយ្យនាអនាគតកុំបីខានឡើយ ។

ជាពិសេសសូមឱ្យលោកធាតុនេះ ដែលជាពិភពសម្រាប់ជ្រកនៅនៃសត្វនិករគ្រប់ពុនបាត់ភយ័ទៅ ឱ្យត្រឡប់បាននូវក្តីសុខវិញគ្រប់ទិសទីកុំបីឃ្លាតឆ្ងាយទៅជាបការដទៃឡើយ ។

**ភិក្ខុ ចិរវិនយោ លាស់ ឡាយ**

វត្តមហាមន្ត្រី ភ្នំពេញ ព.ស.២៥១៧ គ.ស. ១៩៧៣

# បណាមគាថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

### ១ ـ សង្ខារបរិយាយ

សភាវធម៌ទាំងអស់ ដែលកើតឡើងដោយសារបច្ច័យមានអវិជ្ជាជាដើមប្រជុំតាក់តែង ដូចរាងកាយរបស់មនុស្ស អមនុស្ស ទេវតា សត្វតិរច្ឆានដែលមានចិត្ត-វិញ្ញាណ ដឹងសុខ-ដឹងទុក្ខ រួមអាស្រ័យនៅ ដែលហៅថា **ឧបាទិន្នកៈ** នោះក្តី ។

វត្ថុធម្មជាតិដែលកើតឡើង ដោយសារធម្មតាលោក ជាស្វ័យប្រវត្តិ មិនមានចិត្តវិញ្ញាណ ឥតដឹងសុខ-ទុក្ខ ដូចទឹកដីព្រៃភ្នំ ថ្មលោហៈ ឬវត្ថុដែលមនុស្សប្រឌិតដាំបណ្តុះឱ្យកើតឡើងដូចគុម្ពផ្កាច្បារដំណាំនិងទព្វសម្ភារៈផ្សេងៗ មានគ្រឹះស្ថានសណ្ឋាគារធំ-តូច គ្រឿងចក្រយន្តជាដើម ដែលហៅថា អនុបាទិន្នកៈនោះក្តី ។ ទាំងអស់នេះហៅថា **សង្ខារ** ។

ម្យ៉ាងទៀតសង្ខារនេះបើនិយាយតាមអាគតដ្ឋានវិញ បានដល់មនុស្សសត្វ និងវត្ថុធម្មជាតិផ្សេងៗ ដែលកើតឡើងហើយវិនាសទៅវិញ តាមគតិធម្មតាដូចន័យថា (សព្វសត្វទាំងអស់ឋិតនៅបាន អាស្រ័យដោយសារអាហារជាបច្ច័យ) សូម្បីនាមរូបក្តី.វេទនាទាំង៣ក្តី.អាហារទាំង៤ក្តី.ឧបាទានក្ខន្ធទាំង៥ក្តី. អជ្ឈត្តិកាយតនៈទាំង៦ក្តី. វិញ្ញាណដ្ឋិតិទាំង៧ក្តី. លោកធម៌ទាំង៨ក្តី. សត្តាវាស(១)ទាំង៩ក្តី.អាយតនៈទាំង១០ឬ១២ក្តី.ធាតុទាំង១៨ក្តី

(១) សត្តាវាសទាំង៩គឺ នានត្តកាយានានត្តសញ្ញី១ នានត្តកាយាឯកត្តសញ្ញី១ ឯកត្តកាយាឯកត្តកាយាឯកត្តសញ្ញី១ អសញ្ញីភព១ អរូបភូម៤.១ ។ប៉ុន្តែបើលើកអសញ្ញីភព១ អរូបភូមិ៤.១ចេញនៅសល់៧ហៅថាវិញ្ញាណដ្ឋិតិ ។

ទាំងអស់នេះនោះមានវិញ្ញាណឬឥតវិញ្ញាណដែលកើតឡើងហើយ សុទ្ធតែជាបច្ច័យនៃសេចក្តីវិនាសទៅវិញតាមធម្មតានៃសង្ខារលោក. ក៏លោករាប់បញ្ចូលហៅថាសង្ខារដែរ ។

សង្ខារក្នុងទីនេះ យើងសូមពណ៌នាតែអំពីសង្ខារពីរយ៉ាង តែមុននិងពណ៌នានូវសង្ខារទាំងពីរយ៉ាងនោះ យើងសូមអធិប្បាយអំពី **សង្ខារសព្ទ** នេះសិន ។

ពាក្យថាសង្ខារនេះមកពីបទថា **ស** និង **ករៈ** ធ្វើរួម. កសាងរួមផ្គុំអប់រំតាំពារ .បទវិគហថា: **សំ ឯកតោ ករយិន្តាតិ សង្ខារោ** . សភាវៈធម៌ធ្វើរួមគ្នា. គឺរូមនាមធម៌ និងរូបធម៌ឱ្យចូលគ្នាបង្កើតបានទៅជាកាយនគរ ល្អឬអាក្រក់១ ហៅថាសង្ខារ ។

**ឧទាហរណ៍** សេចក្តីថានគរឬរដ្ឋធានី ទីក្រុងផ្ទះសណ្ឋាគារដែលគេកសាងបានល្អឬមិនល្អនោះ អាស្រ័យមកពីសម្ភារវត្ថុ (គ្រឿងសំណង់) បើសម្ភារវត្ថុដែលប្រុងនឹងយកមកធ្វើនោះល្អ នគរឬផ្ទះនោះ ក៏បានស្អាតស្អំល្អ បើសម្ភារវត្ថុនោះមិនល្អទេ នគរឬផ្ទះនោះមេជាងក៏មិនអាច នឹងធ្វើឱ្យស្អាតស្អំបានឡើយ ។

ឯនគរកាយរបស់មនុស្សទេវតាក៏ដូច្នោះដែរ បើសម្ភារៈគឺកុសលផលបុណ្យផ្សំមកជាមួយនិងសន្តានចិត្តច្រើន អភិសង្ខារជាតួចេតនាកម្ម ក៏កសាងរូបរាងកាយនគរអ្នកនោះឱ្យបានស្អាតស្អំ ល្អដែរ បើសម្ភារៈគឺ អកុសលផលបាបជាប់មកជាមួយនិងសន្តានចិត្តច្រើន មេជាងគឺអភិសង្ខារជាតួចេតនាកម្មខាងអកុសលនោះ ក៏កសាងរូបរាងកាយនគរនោះឱ្យវិកលវិការមិនបានល្អឱ្យរហេមរហាមខ្វះខាតជានិច្ចនិរន្តរ៍ ។

តាមគតិធម៌នេះ ភារកិច្ចស្រេចលើ អភិសង្ខារ (សំណាង) បុណ្យបាបល្អអាក្រក់ ដែលមនុស្សសត្វបានសន្សំទុកមកអំពីអតីតនិងបច្ចុប្បន្នដោយបច្ច័យរបស់អវិជ្ជានោះ គាត់តែងចាត់ចែង ចែកជាតិ ភព សម្បត្តិនិងឋានៈ មនុស្សសត្វទៅតាឱ្យមានរូបភាពភ័ព្វវាសនាសំណាងខុសគ្នា មានស្ថានសួគ៌ នរក ៗទៅដោយអភិសង្ខារទាំង៣ គឺ បុញ្ញាភិសង្ខារ១ អបុញ្ញាភិសង្ខារ១ អានេញ្ជាភិសង្ខារ១ អភិសង្ខារណាមួយ ដែលមនុស្សសត្វ បានសាងសន្សំទុកក្នុងចិត្តនោះ ។

តាមសេចក្តីសង្កេតយល់របស់មនុស្សលោកខ្លះថា មនុស្សកើតមកពីមនុស្សគ្មានសភាវៈធម្មជាតិ បុណ្យបាបអ្វីជួយបង្កើតទេ. ថានេះក៏ត្រូវដែរ ប៉ុន្តែត្រូវតែមួយភាគបី(១/៣)ដោយគេភ្លេចនូវមូលហេតុជាតិឬក៏ខ្វះកម្មស្សកតាញាណគឺប្រាជ្ញាដឹងច្បាស់ថាសត្វមានកម្មជារបស់ខ្លួន មានកម្មជាមូល. ហេតុដែលនាំឱ្យសត្វកើតមាន៣យ៉ាងគឺ ១. <u>**គតិរបស់ បដិសន្ធិវិញ្ញាណ**</u> នៃសត្វដែលបំរុងមកកើតក៏មានប្រាកដ. ២. <u>**ចេតនាកម្ម**</u> ដែលមានអវិជ្ជាជាបច្ច័យសម្រាប់ដឹកនាំនូវគតិបដិសន្ធិវិញ្ញាណ នៃសត្វឱ្យមកកើតក្នុងផ្ទៃនៃមាតាដែលមានរដូវកើតព្រមនោះក៏មានប្រាកដ ។

៣. <u>**ការរួមសំវាស**</u> របស់មាតាបិតាក៏ប្រាកដឡើង ។ កាលបើប្រាកដដោយមូលហេតុទាំង៣នេះ ទើបសត្វកើតឡើងបាន ។

ឯមនុស្សគឺមាតាបិតានោះគ្រាន់តែជាទ្រនំជានាទីរបស់គតិនៃបដិសន្ធិវិញ្ញាណជាដើមប៉ុណ្ណោះ. បើគ្មានគតិបដិសន្ធិវិញ្ញាណ និងចេតនាកម្មទេក៏មនុស្ស គឺមាតាបិតាមិនអាចញុំាងមនុស្សឱ្យកើតបានឡើយ ។

ឯពាក្យថាមនុស្សបង្កើតមនុស្សនោះ គ្រាន់តែជាពាក្យកំផ្លែងជាពាក្យ.

គ្មានន័យ ជាបញ្ហារាក់ទាល់ច្រកគ្មានផ្លូវចេញ. ព្រោះហេតុអ្វី ? ព្រោះហេតុថា គេឃើញមនុស្សខ្លះ ធ្វើមនុស្សមិនកើត មនុស្សខ្លះសុទ្ធតែស្រី. ខ្លះសុទ្ធតែប្រុស មនុស្សខ្លះកើតមកខ្វិន ខ្វាក់ គមគាក់ ក្រែងក្រង់ ខ្វះខាតសរីរាវៈយវៈវិកលវិការមិនគ្រប់លក្ខណសម្បត្តិ ទោះស្ត្រីឬបុរសក៏ដោយ មនុស្សខ្លះកើតមកអាប់ឥតប្រាជ្ញា. មនុស្សខ្លះកើតមកបរិបូណ៌ដោយសតិ. បញ្ញា មានរូបសម្បត្តិគួរជាទីទស្សនា ។ ទាំងនេះតើទាស់មកពីមាតាបិតាមិនប៉ិនប្រសព្វបង្កើតឬ ? ឬទាស់មកពីខ្វះអង្គនៃមូលហេតុ ? តាមមតិពុទ្ធសាសនាថា មិនទាស់មកពិមាតាបិតាមិនប៉ិនប្រសព្វបង្កើតនោះទេ. គឺខុកមកអំពីកម្ម-ផលដែលសាមីរូបបានកសាងជាប់មកជាមួយ និងគតិនៃបដិសន្ធិវិញ្ញាណនោះ ។

រួមសេចក្តីទៅបានន័យថា មនុស្សសត្វកើតមកបានពេញលក្ខណៈ ឬក៏មិនពេញលក្ខណៈនោះត្រូវអាស្រ័យដោយហេតុផលមានគតិបដិសន្ធិវិញ្ញាណនិងកម្មដែលមានអវិជ្ជាជាបច្ច័យ ព្រមទាំងមាតាបិតាទើបកើតបាន. ទោះសត្វជាឧបបាតិកជាតិក៏ដោយ ។

ដូច្នេះ ការកើតរបស់មនុស្សសត្វ នៅតែសម្រេចភារកិច្ចលើសង្ខារដដែល. ព្រោះគតិបដិសន្ធិវិញ្ញាណ និងចេតនាកម្ម ក៏ហៅថាសង្ខារ . មនុស្សអ្នកបង្កើតក៏ហៅថាសង្ខារ ។

## អំពីសង្ខារ

**អវិជ្ជាបច្ចយា សង្ខារា សង្ខារសន្តាន**

**អាគត សង្ខារាជាតិ ឧត្តរា សង្ខារា ៗ**

**សង្ខារ មានពីរយ៉ាងគឺ:**

ក. **អវិជ្ជាបច្ចយា សង្ខារា** សង្ខារធម៌ដែលកើតឡើងដោយសារឧបការប្បច្ច័យរបស់អវិជ្ជា ។

ខ. **សង្ខារសទ្ទេន អាគតសង្ខារ** សង្ខារធម៌ដែលកើតចំហាយមកឬខ្ជីរចេញមកដោយសារសម្ទេងនៃសង្ខារ(**គឺអវិជ្ជាបច្ចយានោះ**)។

ក. **អវិជ្ជាបច្ចយាសង្ខារ** មាន៦យ៉ាងគឺ:

បុញ្ញាភិសង្ខារ១. អបុញ្ញាភិសង្ខារ១. អានេញ្ជាភិសង្ខារ១. កាយសង្ខារ១. វចីសង្ខារ១. ចិត្តសង្ខារ១. ។

១. បុញ្ញាភិសង្ខារ សំណាងវាសនាល្អ គឺបុណ្យកុសលដែលមនុស្សសត្វបានសាងសន្សំទុកក្នុងចិត្ត. បានដល់លោកិយកុសលចេតនា ១៣ គឺ កាមាវចរកុសលចេតនា ៨ រូបាវចរកុសលចេតនា ៥ ។

**កាមាវចរកុសលចេតនា ៨** នោះគឺ:

១. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្ត ប្រកបដោយសោមនស្សវេទនា(១) និងព្រមដោយប្រាជ្ញាឥតអ្នកណាដឹកនាំ ១. ។

២. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តប្រកបដោយ សោមនស្ស. វេទនា និងព្រមដោយប្រាជ្ញាប្រកបដោយការដឹកនាំ ១. ។

៣. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តប្រកបដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញាឥតអ្នកណាដឹកនាំ ១. ។

៤. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តប្រកបដោយសោមនស្សវេទនា ប្រាសចាកប្រាជ្ញាប្រកបដោយការដឹកនាំ ១ ។

(១)**យថា ឧបេក្ខា-ចិត្តំ ឧគ្គតិ គណ្ឋសង្គំ តិលសមិសំ ហោតិ.** ពេលណាឧបេក្ខាចិត្តប្រព្រឹត្តទៅ ពេលនោះហទយលោហិតថ្លាថ្លង់ដូចប្រេងល្ង ។

៥. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តប្រកបដោយឧបេក្ខាវេទនា(១) និងព្រមដោយប្រាជ្ញា ឥតអ្នកណាដឹកនាំ ១ ។

៦. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា និងព្រមដោយប្រាជ្ញាប្រកបដោយការដឹកនាំ ១ ។

៧. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា ប្រាសចាកប្រាជ្ញាឥតអ្នកណាដឹកនាំ ១ ។

៨. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា ប្រាសចាកប្រាជ្ញាប្រកបដោយការដឹកនាំ ១. ។

**បញ្ញាភិសង្ខារោ ទានសីលាទិវសេន បវត្តា**
**អដ្ឋ កាមាវចរកុសលចេតនា ។**

កាមាវចរកុសលចេតនាទាំងឡាយណាមួយនោះ សម្រេចដាច់ខាតដោយគុណមានទានមយៈ សីលមយៈ ជាអាទិ៍ឈ្មោះបុញ្ញាភិសង្ខារជាបុញ្ញកិរិយាវត្ថុរបស់មនុស្សសត្វត្រូវបំពេញ ដើម្បីបាននូវមនុស្សសម្បត្តិនិងទេវសម្បត្តិក្នុងកាមាវចរភព ។

(កាមាវចរមហាកុសលចេតនា ៨ ចប់)

## ឯរូបាវចរកុសលចេតនា ៥ នោះគឺ

១. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តជាបឋមជ្ឈានមានអង្គ ៥

---

(១) **យទា ឧបេក្ខា-ចិត្តំ វត្តតិ តទា ហទយំ តិលសទិសំ ហោតិ**. ពេលណាឧបេក្ខាចិត្តប្រព្រឹត្តទៅ. ពេលនោះហទ័យលោហិតថ្លាឲ្យដូចប្រេងល្ង ។

២. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តជាទុតិយជ្ឈានមានអង្គ ៤ ។
៣. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តជាតតិយជ្ឈានមានអង្គ ៣ ។
៤. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តជាចតុត្ថជ្ឈានមានអង្គ ២ ។
៥. ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងកុសលចិត្តជាបញ្ចមជ្ឈានមានអង្គ ២ ។

**ភាវនាវសេនេវ បវត្តា បញ្ច រូបាវចរកុសលចេតនា**

រូបាវចរកុសលចេតនាទាំង៥ ណាមួយនោះ សម្រេចដាច់ខាតដោយភាវនាមយៈ ជាបុញ្ញកិរិយាវត្ថុរបស់មនុស្សសត្វត្រូវបំពេញ ដើម្បីបាននូវទេវសម្បត្តិក្នុងកាមាវចរភព ។

( រូបាវចរកុសលចេតនា ៥ ចប់

រួមគ្នាត្រូវជាលោកិយកុសលចេតនា ១៣ ជាអ្នកតាក់តែងនូវជាតិភពសម្បត្តិ និងដឹកនាំមនុស្សសត្វ ឱ្យទៅកើតក្នុងកាមាវចរភព និងរូបាវចរភព ហៅថា បុញ្ញាភិសង្ខារ ។

( បុញ្ញាភិសង្ខារចប់ ) ។

២. អបុញ្ញាភិសង្ខារ សំណាងវាសនាអាក្រក់គឺអកុសលផលបាប ដែលមនុស្សសត្វបានប្រព្រឹត្តសាងសន្សំទុកក្នុងចិត្ត ។ បានដល់លោកិយអកុសលចេតនា ១២ គឺចេតនាកម្មដែលប្រព្រឹត្តទៅក្នុងអកុសលលោភចិត្ត ៨ អកុសលទោសចិត្ត ២ អកុសលមោហចិត្ត ២ ។

**ឯចេតនាកម្មដែលប្រព្រឹត្តទៅក្នុងអកុសលលោភចិត្ត ៨ នោះគឺ:**

៖ លោភចិត្តប្រកបដោយសោមនស្សវេទនា និងព្រមដោយទិដ្ឋិ(១) ពីរប្រការឥតអ្នកណាដឹកនាំ ១.

(១) ទិដ្ឋិ២ប្រការគឺ សស្សតទិដ្ឋិ១. ឧច្ឆេទទិដ្ឋិ១ ។មិច្ឆាទស្សនមេវ ទិដ្ឋិតិ វុច្ចតិទស្សនៈដែលយល់ច្រឡំនឹងឯង ហៅថាទិដ្ឋិ (អភិធម្មត្ថវិភាវិនី) ។

፡፡ លោភចិត្តប្រកបដោយសោមនស្សវេទនា ព្រមដោយទិដ្ឋិពីរប្រការ ប្រកបដោយការដឹកនាំ ១. ។

፡፡ លោភចិត្តប្រកបដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិពីរប្រការឥតអ្នកណាដឹកនាំ ១. ។

፡፡ លោភចិត្តប្រកបដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិពីរប្រការ ប្រកបដោយការដឹកនាំ១ ។

፡፡ លោភចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយទិដ្ឋិពីរប្រការ ឥតអ្នកណាដឹកនាំ ១ ។

፡፡ លោភចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយទិដ្ឋិពីរប្រការ ប្រកបដោយការដឹកនាំ ១. ។

፡፡ លោភចិត្តក្របដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិពីរប្រការ ឥតអ្នកណាដឹកនាំ ១

፡፡ លោភចិត្តប្រកបដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិពីរប្រការ ប្រកបដោយការដឹកនាំ ១ ។

( លោភចិត្តអកុសលចេតនាកម្ម ៨ ចប់ )

**ឯចេតនាកម្មដែលប្រព្រឹត្តទៅក្នុងអកុសលទោសចិត្ត២នោះគឺ:**

፡፡ ទោសចិត្តប្រកបដោយទោសមនុស្សវេទនា(១) ព្រមដោយសេចក្ដីថ្នាំងថ្នាក់ឥតអ្នកណាដឹកនាំ ១ . ។

(១) យថា ទោសមនុស្សចិត្តំ វត្តតិ តថា កាឡកំ ជម្ពុបក្កសទិសំ ហោតិ. ពេលណាទោមនស្សចិត្តប្រព្រឹត្តទៅ. ពេលនោះហទយលោហិតមានពណ៌ខ្មៅដូចផ្លែព្រីងទុំ ។

៚ ទោសចិត្តប្រកបដោយទោមនស្សវេទនា ព្រមដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយការដឹកនាំ ១ . ។

( ទោសចិត្តអកុសលចេតនាកម្ម ២ ចប់ )

**ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងអកុសលមោហចិត្ត ២ នោះគឺ:**

៚ មោហចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយសេចក្តីសង្ស័យ ១.។

៚ មោហចិត្តប្រកបដោយឧបេក្ខាវេទនាព្រមដោយសេចក្តីរាយមាយ ១.។

( មោហចិត្តអកុសលចេតនាកម្ម ២ ចប់ )

**អកុសលមូលទាំង ៣ នេះលោកសង្គ្រោះជា៥ចំណែកគឺ:**

១. ឆន្ទ:(ឆន្ទោ នាម បុព្វុប្បត្តិកា ទុព្វលតណ្ហា សោ រជ្ជេតុំ នសក្កោតិ) តណ្ហាមានកម្លាំងខ្សោយ ដែលកើតឡើងជាដំបូងៗ ឈ្មោះថាឆន្ទ:. ឆន្ទ:នោះវាមិនអាចត្រេកត្រអាលបានទេ ។

២. រាគ: (អបរាបរំ ឧបជ្ជមានា បន ពលវតណ្ហា រាគោ នាម សោ រជ្ជេតុំ សក្កោតិ) ឯតណ្ហាមានកម្លាំងខ្លាំង ដែលវាកើតបន្តគ្នាថែម ទៀតឈ្មោះថារាគ: . រាគ:នោះវាអាចត្រេកត្រអាលបានតាមចិត្ត. (ទាំងពីរនេះចាត់ចូលក្នុងលោភសហគតចិត្ត) ។

៣. ទោស: (ទណ្ឌាទានាទីនិ កាតុំ សមត្ថោ បុព្វុប្បត្តិកោ ទុព្វលកោធោ ទោសោ នាម) សេចក្តីក្រេវក្រោធមានកម្លាំងខ្សោយ ដែលវាកើតជា ជាដំបូងៗ ឈ្មោះថាទោស: វាអាចធ្វើនូវអំពើទាំងឡាយមានកាន់យក នូវដំបងជាដើមបាន (តែមិនអាចវាយបានទេ) ។

៤. បដិឃ: (តានិ កាតុំ សមត្ថោ អបរាបរុប្បត្តិកោធោ បដិឃំ នាម)

សេចក្តីក្រេវក្រោធមានកម្លាំងខ្លាំង ដែលវាកើតបន្តគ្នាថែមហើយថែមទៀត ឈ្មោះថាបដិឃៈ វាអាចធ្វើនូវទណ្ឌកម្មជាអាទិ៍នោះបានពេញទី (ទាំងពីរនេះចាត់ចូលក្នុងទោមនស្សសហគតចិត្ត) ។

៥. អញ្ញាណៈ (មោហោ បន មោហនបមោហនវសេន ឧប្បន្នំ អញ្ញាណំ) ឯក្តីក័ន្តប្រឡុំគឺមោហៈបានដល់ការមិនដឹងនូវក្តីពិតដែលវាកើតដោយអំណាចនៃមោហ័ននិងបមោហ័ននោះឈ្មោះថាអញ្ញាណៈ .

( ១នេះចាត់ចូលក្នុងឧទ្ធច្ចវិចិកិច្ឆាសហគតចិត្ត )

អកុសលចេតនាទាំង១២ណាមួយនោះជាអ្នកតាក់តែងចែកជាតិ.កំណើតទីឋានមនុស្សសត្វឱ្យទាបថោកខុសគ្នាគឺ:

១. បើមនុស្សណាល្មោភលោភលន់ពានគ្មានសេចក្តីសន្តោសសង្គ្រោះអ្នកណាមួយនោះ. អកុសលចេតនាកម្មជាតួអភិសង្ខារនេះ និងប្រាទមនុស្សនោះឱ្យប្រទះតែសេចក្តីក្រិក្រហិនហោចរហេមរហាមខ្វះគ្រឿងឧបភោគជានិច្ច ព្រោះខ្វះគុណធម៌គឺផលទាន ។

២. បើមនុស្សណាពាលសាហាវយង់ឃ្នងកាចឃោរឃៅជិះជាន់ធ្វើបាបមនុស្សដែលមិនមានកម្លាំង ឬខ្សោយជាងខ្លួន.អំពើទ្រុស្តនោះនិងផ្តល់ឱ្យខ្លួនវិញនូវអំពើដ៏ជូចត់ មានកើតមកជាមនុស្សវិកលវិការ ខ្វាក់ភ្នែក កំបុតដៃ.ជើងឆ្កួតលីលា ជាដើមព្រោះខ្វះគុណគឺសីលធម៌ ។

៣. បើមនុស្សណាមានគំនិតអធ្យាស្រ័យស្មាក់ស្មើរ វាយមាយគ្មានសិក្សារៀនសូត្យអ្វីនិងគេ ទោះផ្លូវលោកឬផ្លូវធម៌ វង្វេងយល់ច្រឡំតែម្នាក់ឯងអកុសលកម្មនោះ ក៏កសាងជាតិភពវិបត្តិ ឱ្យអ្នកនោះទៅជាមនុស្សខ្វះខាតសតិប្រាជ្ញាមិនគ្រប់គ្រាន់ មិនបរិបូណ៌ .ព្រោះគ្មានគុណធម៌ភាវនាការរៀនសូត្រការអប់រំទុកក្នុងសន្តានចិត្ត ។

មិនតែប៉ុណ្ណោះទេអកុសលចេតនាកម្មជាតួអភិសង្ខារនេះ អាចកសាងទីឋានដ៏លាមកទាបថោកមានឋាននរកប្រេតជាដើម ហើយនាំបណ្ដើរអ្នកនោះឱ្យទៅទទួលរងទុក្ខទោស ដោយអំពើទាបថោករបស់ខ្លួននោះទៀត ។

**អបុញ្ញាភិសង្ខារោ តណ្ហាតិចាតាទិវសេន បវត្តា ទ្វាទស អកុសលចេតនា ។**

លោកិយអកុសលចេតនាទាំង ១២ នេះប្រព្រឹត្តដោយអំពើមានតណ្ហាតិចាតជាដើមលោកហៅថា អបុញ្ញាភិសង្ខារ ។

( អបុញ្ញាភិសង្ខារចប់ )

៣. **អានេញ្ជាភិសង្ខារ** អភិសង្ខារគឺវាសនាបុណ្យកុសល ដែលមនុស្សសត្វបានកសាងសន្សំទុកក្នុងសន្ដានចិត្ត ដោយអរូបជ្ឈានទាំង៤មិនញាប់ញ័រដោយរូបធម៌ ។ បានដល់ចេតនាកម្មដែលប្រព្រឹត្តទៅក្នុងអរូបាវចរកុសលចិត្តទាំង៤ គឺ:

១.អាកាសានញ្ចាយតនៈ សម្លឹងអាកាសដែលជាវង់របស់កសិណជាអារម្មណ៍របស់ចិត្ត ដោយបរិកម្មថា<អាកាសោអនន្តោ> អាកាសមិនមានទីបំផុត ។

២.វិញ្ញាណញ្ចាយតនៈ សម្លឹងយកអរូបវិញ្ញាណជាអារម្មណ៍នៃចិត្តដោយបរិកម្មថា <វិញ្ញាណំ អនន្តំ អរូបំ> អរូបវិញ្ញាណមិនមានទីបំផុត ។

៣. អកិញ្ចញ្ញាយតនៈ សម្លឹងយកភាពនៃអរូបវិញ្ញាណជាអារម្មណ៍នៃចិត្តដោយបរិកម្មថា <នត្ថិ កិញ្ចិ> វត្ថុណាមួយមិនមាន ។

៤. នេវសញ្ញានាសញ្ញាយតនៈ សម្លឹងយកទស្សនៈនៃអរូបវិញ្ញាណជាអារម្មណ៍នៃចិត្តដោយបរិកម្មថា< សញ្ញាមិនមានតែមិនមែនជាគ្មានសញ្ញា >។

## អានេញ្ជាភិសង្ខារ [illegible]

## ចតុក្កា ចតស្សោ អរូបាវចរកុសលចេតនា ៤

អរូបាវចរកុសលចេតនាកម្មទាំង៤ណាមួយនោះ ប្រព្រឹត្តដាច់ខាតដោយភាវនាកម្មសុទ្ធជាអ្នកកសាងនូវជាតិ ភព សម្បត្តិតាមគតិនៃអរូបជ្ឈានទឹងជីកនាំឱ្យទៅក្នុងអរូបភព គឺព្រហ្មលោកជាន់ខ្ពស់ ជាកំណត់មិនត្រេកអរក្នុងកាមគុណដោយអានុភាពអានិសង្សនៃអរូបសមាបត្តិ ប៉ុន្តែថ្នាក់ជាលោកិយក៏មានថ្នាក់ជាអនាគាមិបុគ្គលដល់អរហត្តលោកុត្តរៈ ហើយបរិនិព្វានក្នុងទីព្រហ្មលោកនោះទៅក៏មាន លោកហៅថា <u>អានេញ្ជាភិសង្ខារ</u> ។

រួមចេតនាកម្មទាំងអស់គឺ កាមាវចរកុសលចេតនា ៨ រូបាវចរកុសលចេតនាចេតនា៥អកុសលចេតនា១២ < សម្រាប់អបុញ្ញាភិសង្ខារ > អរូបាវចរកុសលចេតនា ៤< សម្រាប់អនេញ្ជាភិសង្ខារ > ត្រូវជា ២៩ ហៅថាលោកិយកុសលាកុសលចេតនា ។ ( អានេញ្ជាភិសំខារចប់ )

**៤.កាយសង្ខារ** សភាវធម៌ដែលជួយអប់រំតាំការកាយបានដល់កាយសញ្ចេតនា គឺចេតនាដែលសម្បយុត្តក្នុកាយរបស់មនុស្ស ។

**កាយសញ្ចេតនា**(១)នេះលោកសំដៅយកចេតនា ២០ គឺកាមាវចរកុសលចេតនា៨ អកុសលចេតនា១២ ដែលញ៉ាំងកាយវិញ្ញត្តិឱ្យកើតហើយប្រព្រឹត្តទៅក្នុងកាយទ្វារ ។

(១)កាយសញ្ចេតនាពិស្តារមាន៨០គឺៈ១.សយំកតមូលកាចេតនា(ចេតនាកម្មដលជាមូលហេតុនៃកម្មដែលគេធ្វើបានដោយខ្លួនឯង. អសង្ខារិកចេតនា) ២០.(មហាកុសល៨អកុសល១២) ។
២. អានត្តិមូលកាចេតនា(មូលកាចេតនាប្រកបដោយបញ្ញា សសំខារិកចេតនា)២០.។
៣. សម្បជានមូលកាចេតនា(មូលកាចេតនាប្រកបដោយប្រាជ្ញា.ញាណសម្បយុត្ត)២០,
៤. អសម្បជានមូលកាចេតនា(មូលកាចេតនាប្រាសចាកប្រាជ្ញា.ញាណវិប្បយុត្ត)២០
( [illegible] ) ( [illegible] ) ។

សេចក្ដីថា: មនុស្សសត្វទាំងឡាយក្នុងលោកនឹងកសាង ឬធ្វើបុណ្យ-ធ្វើបាបក្ដី លុះតែកំរើកដៃជើងឱ្យកើតតាមកាយទ្វារទើបកសាងធ្វើបុណ្យ-ធ្វើបាបជាដើមនោះបាន ។ ហេតុនោះចេតនាទាំង២០ណាមួយនោះលោកហៅថាកាយសញ្ចេតនា ព្រោះចេតនាកម្មទាំងនេះជាតួបុណ្យ-បាបក្នុងកាយសង្ខារនេះ ។ ម្យ៉ាងទៀតសូម្បីខ្យល់ដកដង្ហើមចេញចូលដែលហៅថាអស្សាសបស្សាសៈនោះក៏ហៅថាកាយសង្ខារដែរ ។

ព្រោះខ្យល់អស្សាសបស្សាសៈនោះជាប់ទាក់ទងតាមផ្លូវកាយ ប្រស់ព្រំកាយឱ្យស្រស់បស់មិនឱ្យស្វិតស្រពោន ។

( កាយសង្ខារ ចប់ )

**៥. វចីសង្ខារ** សង្ខារគឺសំពីបានដល់ចេតនាដែលប្រព្រឹត្តទៅក្នុងវចីទ្វារហៅថាវចីសញ្ចេតនា(១)ៗនេះ លោកសំដៅយកចេតនាទាំង ២០ គឺកាមាវចរកុសលចេតនា៨ អកុសលចេតនា១២ ។

មនុស្សទាំងអស់ក្នុងលោកបើមានបំណងនិងនិយាយល្អឬអាក្រក់រមែងតែញាំងវចីវិញ្ញត្តិឱ្យចេញទៅតាមវចីទ្វារជាមុនទើបបញ្ចេញ ឬបញ្ជានូវកិច្ចការបុណ្យ-បាប ឬល្អអាក្រក់នោះបានជាខាងក្រោយ។ ហេតុនោះចេតនាកម្មទាំង២០ ណាមួយនោះដែលជាអ្នកតាក់តែងថ្លៃសំពីមនុស្សឱ្យល្អ ឬអាក្រក់ក្នុងទីនេះលោកហៅថា វចីសង្ខារ ។

ម្យ៉ាងទៀតវិតក្កៈ សេចក្ដីត្រិះរិះ . វិចារៈ ការពិចារណាដោយវិចារណញ្ញាណ. មុននិងបញ្ចេញនូវសំពីនោះក៏លោកហៅថាវចីសង្ខារដែរ។ ព្រោះថាវាចា គឺ សំពីនេះ បើគេនិយាយដោយសេចក្ដី ត្រិះរិះមុន

(១) វចីសញ្ចេតនាពិស្ដារសម្រាប់វចីទ្វារមាន ៨០ ដូចកាយសញ្ចេតនាដែរ ។

ឬដោយវិចារណញ្ញាណ. រមែងមានប្រយោជន៍ បានបុណ្យយសសក្តិនឹងលាភសក្ការៈ បើគេនិយាយដោយឥតត្រិះរិះឬក៏ខ្វះវិចារណញ្ញាណទៅជាឥតប្រយោជន៍ គ្មានតម្លៃ បានបាប មានទោសពៃរ ខាតលាភសក្ការៈធ្លាក់យស.សក្តិ ហេតុនេះ វិតក្កៈនឹងវិចារៈ នេះជាការចាំបាច់របស់មនុស្សក្នុងវចីសង្ខារនេះ ។

( វចីសង្ខារ ចប់ )

៦. ចិត្តសង្ខារ. ការតាក់តែងជួយអប់រំតាំពារចិត្ត បានដល់លោកិយកុសលា កុសលចេតនាទាំង២៩ គឺ កាមាវចរកុសលចេតនា៨ អកុសលចេតនា១២ រូបាវចរកុសលចេតនា៥ អរូបាវចរកុសលចេតនា៤ លោកិយចេតនាណាមួយដែលហៅថា <u>មនោសញ្ចេតនា(១)</u> នោះ ។

ធម្មជាតិដែលអប់រំនូវសម្បយុត្តធម៌ទាំងឡាយ ព្រមទាំងទុកក្នុងចិត្តារម្មណ៍ ហៅថាមនោសញ្ចេតនា គឺចេតនាកម្មដែលជួយអប់រំតាំពារចិត្តឱ្យប្រព្រឹត្តទៅតែក្នុងមនោទ្វារ មិនឱ្យធ្វើកាយវិការឬកាយវិញ្ញត្តិ វចីវិញ្ញត្តិ. ទោះអំពើនោះជាបុណ្យឬបាបគុណឬទោសសុខឬទុក្ខ សប្បាយរីករាយ ឬក្រៀមក្រំក៏ដោយ ។

គឺបុណ្យបាបដែលកើតតាមផ្លូវចិត្ត ជារស្មីរបស់ចិត្ត ជាអំណោយផលរបស់ចិត្ត ឥតធម្មជាតិធ្វើឱ្យរលុបបាន លោកហៅថាចិត្តសង្ខារ ។

(១) មនោសញ្ចេតនាពិស្តារមាន១១៦ គឺ ១.សយំកតមូលកាចេតនា២៩ ( មហាកុសល៨ រូបាវចរកុសល៥ អកុសល១២ អរូបាវចរកុសល៤ ) ២អាណត្តិមូលកាចេតនា២៩. ៣.សម្បជានមូលកាចេតនា២៩ ។ ៤. អសម្បជានមូលកាចេតនា ២៩. ជា១១៦ (សម្រាប់មនោទ្វា) ។ បើរួមទ្វាំង ៣ ត្រូវជា ២៧៦ ចេតនា ។(ចតុក្កង្គុត្តរនិកាយដ្ឋកថា ។

ម្យ៉ាងទៀតសញ្ញានិងវេទនា ក៏លោកហៅថាចិត្តសង្ខារដែរ ព្រោះសញ្ញាសេចក្តីកត់ចំណាំនូវអ្វីៗ ក្តី. វេទនាធម្មជាតិទទួលរងទទួលសោយនូវអារម្មណ៍ផ្សេងៗក្តី តែងជាប់ទាក់ទងជាមួយនិងចិត្តជួយអប់រំគាំពាចិត្តឱ្យចាំច្បាស់ឱ្យរងនូវអារម្មណ៍ផ្សេងៗ ទោះអារម្មណ៍នោះល្អ ឬអាក្រក់ក៏ដោយ ។

សង្ខារធម៌ទាំង ៣ នេះកាលកើតឡើង ចិត្តសង្ខារកើតមុន បន្ទាប់មកទើបកើតកាយសង្ខារវចីសង្ខារកើតក្រោយបំផុត លុះរលត់ស្លាប់ទៅវិញ កាយសង្ខាររលត់មុន ទើបវចីសង្ខាររលត់ទៅជាបន្ទាប់ ចិត្តសង្ខាររលត់ក្រោយបំផុត ។ ( ចិត្តសង្ខារ ចប់ )

( ចប់ អវិជ្ជា បច្ចយា សង្ខារ )

**ខ. សង្ខារសទ្ទេន អាគតសង្ខារ មាន ៤ យ៉ាង គឺ:**

**សង្ខតសង្ខារ ១ អភិសង្ខតសង្ខារ ១**

**អភិសង្ខរណកសង្ខារ ១ បយោគាភិសង្ខារ ១**

១. សង្ខតសង្ខារ: ( **តត្ថ អនិច្ចា វតសង្ខារាតិ អាទីសុវុត្តា សព្វេបិ សប្បច្ចយធម្មា សង្ខតសង្ខារានាម** ) សប្បច្ចយធម៌ទាំងអស់ ដែលលោកពោលទុកក្នុងទីទាំងឡាយមានដើមថា: **អនិច្ចាវត សង្ខារា**. ជាអាទិ៍ ក្នុងចំណោមនោះហៅថា: សង្ខតសង្ខារ ។

សប្បច្ចយធម៌នោះបានដល់ពាក្យថា: សង្ខារធម៌ ( លោកិយកុសលាកុសលចេតនា២៩)ទាំងឡាយកើតឡើងដោយសារឧបការប្បច្ច័យរបស់អវិជ្ជា(១) ( ធម្មជាតិដែលមិនដឹងច្បាស់នូវ ចតុរារិយសច្ច ) ។

(១) អវិជ្ជាជាប្រធានហេតុរបស់សង្ខារ: សង្ខារជាបធានផលរបស់អវិជ្ជា ។
អវិជ្ជាកើតមកពីអាសវ: ៤ ។ កើតមកពីអវិជ្ជា ។

វិញ្ញាណ(១) ទាំង ៣២ កើតឡើងដោយសារឧបការប្បច្ច័យរបស់សង្ខារ ។ នាមរូប <អរូបក្ខន្ធ៣ គឺវេទនា សញ្ញា សង្ខារ ហៅថានាម. រូប២៨ ហៅថារូប រួមគ្នាហៅថានាមរូប> កើតឡើងដោយសារឧបការប្បច្ច័យរបស់វិញ្ញាណ។ អាយតនៈ ទាំង៦ ខាងក្នុង <មតិអាចារ្យខ្លះថាពាហិរាយតនៈដែរ> កើតឡើងដោយសាឧបការប្បច្ច័យរបស់នាមរូប ។

ផស្សៈទាំង៦មានចក្ខុសម្ផស្សជាអាទិ៍<ផស្សៈ៣២ដូចវិញ្ញាណក៏មាន> កើតឡើងដោយសារ ឧបការបច្ច័យរបស់អាយតនៈ > ។

វេទនាទាំង៣ ឬ៦ ឬ ៨៩ កើតឡើងដោយសារឧបការប្បច្ច័យរបស់ផស្សៈ ។ តណ្ហាទាំង ១០៨ កើតឡើងដោយសារឧបការប្បច្ច័យរបស់វេទនា ។ ឧបាទានទាំង ៤ មានកាមុបាទានជាដើមកើតឡើងដោយសារឧបការប្បច្ច័យរបស់តណ្ហា ។ ភពទាំងពីរ <កម្មភព(២) មាន២៩ ឧបបត្តិភព(៣) មាន ៩ កើតឡើងដោយសារឧបការប្បច្ច័យ

(១) វិបាកចិត្ត៣២ ដែលប្រព្រឹត្តទៅក្នុងបដិសន្ធិនិងបវត្តិកាលហៅថាវិញ្ញាណ ។ វិញ្ញាណ ៣២ នោះគឺ មនោធាតុ ២ អហេតុក មនោវិញ្ញាណធាតុ ៣ សហេតុកកាមាវចរវិបាក ៨ អរូបាវចរវិបាក ៤ ទ្វិបញ្ចវិញ្ញាណ ១០ ជា ៣២ ។បណ្ដាវិញ្ញាណទាំង ៣២ នេះ វិញ្ញាណ ២១ គឺអហេតុកកុសលវិបាក ៥ មនោធាតុ ១ មនោវិញ្ញាណធាតុ២ កាមាវចរវិបាក៨ រូបាវចរវិបាក៥ កើតមកអំពីបុញ្ញាភិសង្ខារ ។ វិញ្ញាណ៧ គឺអកុសលវិបាកហេតុក៥ មនោធាតុ១ មនោវិញ្ញាណធាតុ១ កើតមកអំពីអបុញ្ញាភិសង្ខារ ។ វិញ្ញាណ៤ គឺអរូបាវចរវិបាក៤ កើតមកអំពីអានេញ្ជាភិសង្ខារ ។ម្យ៉ាងទៀតវិញ្ញាណទាំង៣២ នេះ វិញ្ញាណ១៣ គឺ ទ្វិបញ្ចវិញ្ញាណ១០ មនោធាតុ២ សោមនស្សអហេតុក មនោវិញ្ញាណធាតុ១ ប្រព្រឹត្តទៅក្នុងបវត្តិកាល ក្នុងបញ្ចវោការភព។ ឯវិញ្ញាណ១៩ គឺអហេតុកមនោវិញ្ញាណធាតុ២ សហេតុកកាមាវចរវិបាក៨ រូបាវចរវិបាក៥ អរូបាវចរវិបាក៤ ប្រព្រឹតទៅក្នុងបវត្តិកាល និងបដិសន្ធិកាលក្នុងភព ៣ ។

(២) គឺចេតនាកម្មដែលកើតពីបុញ្ញាភិសង្ខារ១៣. អបុញ្ញាភិសង្ខារ១២ អានេញ្ជាភិសង្ខារ៤ ជា២៩ ហៅថាកម្មភព ។

(៣) កាមភព១. រូបភព១. អរូបភព១. សញ្ញាភព១. អសញ្ញាភព១. នេវសញ្ញានាសញ្ញាភព១. ឯកវោការភព១. ចតុវោការភព១. បញ្ចវោការភព១. ជា ៩ ហៅថាឧបបត្តិភព ។

LIBRARY

របស់ឧបាទាន ។

ជាតិ <ការបានប្តូរអត្តភាពក្នុងភពនោះ២ > កើតឡើងដោយសារឧបការប្បច្ច័យរបស់ភព ។

**ជរាមរណៈ** <ភាពគ្រាំគ្រានៃអត្តភាពដែលចម្លជាតិកំណត់ក្នុងភពនិមួយៗ> **សោកៈ** <សេចក្តីក្តុកក្តួលក្រៀមក្រំ> **បរិទេវៈ** <ទំនួញរៀបរាប់> **ទុក្ខៈ** <សេចក្តីវេទនុក្ខ លំបាកតាមផ្លូវកាយ> **ទោមនស្សៈ** សេចក្តីទុក្ខលំបាកតាមផ្លូវចិត្ត> **ឧបាយាសៈ**<សេចក្តីចង្អៀតចង្អល់យ៉ាងក្រៀមស្រពោន>កើតឡើងដោយសារឧបការប្បច្ច័យរបស់ជាតិ។ នេះជាបដិច្ចសមុប្បាទធម៌។ ម្នាលភិក្ខុទាំងឡាយម៉្យាងទៀត <<ជរាមរណៈជាដើមនេះជាអនិច្ចធម៌ (សភាវមិនទៀង)ជាសង្ខារធម៌ (សភាពគឺបច្ច័យប្រូតផ្តុំឡើង) ជាបដិច្ចសមុប្បន្នធម៌ (សភាពអាស្រ័យនូវហេតុ.ផល ហើយទើបកើត) ជាខយធម៌ (សភាពអស់រលីង) ជាវយធម៌ (សភាពសោះសូន្យ) ជាវិរាគធម៌ (សភាពតែងនិរាសទៅ) ជានិរោធធម៌ ( សភាពតែងរលត់រលាយ ) >> ។

ឯជាតិ.ភព.ឧបាទាន.តណ្ហា.វេទនា.ផស្ស.សឡាយតនៈ.នាមរូប.វិញ្ញាណ.សង្ខារ.អវិជ្ជា. ក៏ជាអនិច្ចធម៌.ជាសង្ខតធម៌.ជាបដិច្ចសមុប្បន្នធម៌.ជាខយធម៌.ជាវយធម៌.ជាវិរាគធម៌.ជានិរោធធម៌ដែរ (នេះជាបដិច្ចសមុប្បន្នធម៌) រួមបដិច្ចសមុប្បាទធម៌ និង បដិច្ចសមុប្បន្នធម៌ហៅថា សប្បច្ចយធម៌ ព្រោះកើតរលត់សារចុះសារឡើងក្នុងវដ្តសង្សារ ដោយសារសម្ភារប្បច្ច័យ និងការប្រូតផ្តុំនៃសម្ភារធាតុ ដូចពពុះទឹកកើតឡើងហើយបែកធ្លាយទៅវិញជាធម្មតាឥតទៀងទាត់ ។

( សំខតសំខារ ចប់ )

២. **អភិសង្ខតសង្ខារៈ ( កម្មនិព្វត្តា តេភូមិកា រូបារូប ធម្មា អភិសង្ខត-សង្ខារាតិ អដ្ឋកថា-សុ វុត្តា តេបិ អនិច្ចា វតសង្ខារាតិ ឯត្ថេវសង្គហំ គច្ឆន្តិ** ) សង្ខារ គឺរូបធម៌ និង អរូបធម៌ ដែលកើតអំពីកម្មប្រព្រឹត្តទៅក្នុងភូមិទាំង៣ លោកពោលទុកក្នុងអដ្ឋកថាថាៈ អភិសង្ខតសង្ខារ ។ រូបធម៌ និង អរូបធម៌នោះលោកសង្គ្រោះចូលក្នុងត្រក <<**អនិច្ចា វត សំខារា**>> នុ៎ះដែរ ។

**ចិសុំ ឋន នេសំ អាគតដ្ឋានំ នប្បញ្ញាយតិ** ។ ឯអាគតដ្ឋាននៃសង្ខារនោះ ឥតប្រាកដថាផ្សេងគ្នាទេ អធិប្បាយថាៈ រូបធម៌និងអរូបធម៌ ដែលមានសណ្ឋានគ្រោតគ្រាតនិងល្អិតល្អន់និងទន់ជាដើម ដែលជាលោកិយៈនោះ បានដល់រូបទាំង២៨ និង អរូប៥៣ ។ ឯរូប២៨ នោះគឺមហាភូតរូប៤ ឧបាទាយរូប២៤ ។ ឯមហាភូតរូប៤ នោះគឺ មហាភូតរូបដែលជាបឋវីធាតុខាងក្នុង២០គឺៈ **កេសា** សក់។ល។ **មត្ថលុង្គំ** ខួរក្បាល ។ មហាភូតរូបជាអាបោធាតុខាងក្នុង១២ គឺ **បិត្តំ** ទឹកប្រមាត់ ។ល។ **មុត្តំ**(១) ទឹកមូត្រ ។ មហាភូតរូបជាតេជោធាតុខាងក្នុង៤ គឺ **សន្តប្បតិ** ធាតុភ្លើង អប់រំកាយឱ្យក្តៅធម្មតា១ **ជីរយតិ** ធាតុភ្លើងដុតរាងកាយឱ្យចាស់គ្រាំគ្រា១ **បរិឌយ្ហតិ** ធាតុភ្លើងដុតរាងកាយឱ្យក្តៅប្លែកពីធម្មតា១ **បរិណាមតិ** ធាតុភ្លើដុតអាហារឱ្យរលាយឱ្យជ្រួតជ្រាបឱជារសសព្វសព៌ាង្គកាយ១ ។

មហាភូតរូបជាវាយោធាតុខាងក្នុង ៦ គឺ **ឧទ្ធង្គមាវាត** ខ្យល់បក់

(១)មហាភូតរូបជាបឋវីធាតុ និងអាបោធាតុនេះ សូមមើលអភិធម្មត្ថសង្គហៈ ។

ពីក្រោមទៅលើ១ **អធោគមវាត** ខ្យល់បក់ពីលើទៅក្រោម១ **កុច្ឆិសយវាត** ខ្យល់បក់វិលវល់ក្នុងផ្ទៃ១ **កោដ្ឋាសយវាត** ខ្យល់បក់ផ្សាយទៅក្នុងពោះវៀនធំ-តូច១, **អង្គមង្គានុសារីវាត** ខ្យល់បក់ផ្សាយសព្វក្នុងអវយវៈធំ-តូច១**អស្សាសបស្សាសវាត** ខ្យល់ដកដង្ហើមចេញចូល១។

ឯឧបាទាយរូប២៤ នោះគឺ បសាទរូប៥ (ចក្ខុបសាទ, សោតបសាទ, ឃានបសាទ, ជិវ្ហាបសាទ, កាយបសាទ) ។ វិសយរូប ៤ ( រូប,សទ្ទ,គន្ធ,រស, ) ; ភាវរូប២ (ឥត្ថីភាវរូប បុរិសភាវរូប), ហទយរូប១, ជីវិតរូប១, អាហាររូប១, បរិច្ឆេទរូប១, វិញ្ញត្តិរូប ២ (កាយវិញ្ញត្តិ វចីវិញ្ញត្តិ), វិការរូប ៣ (រូបស្សលហុតា, រូបស្សមុទុតា, រូបស្សកម្មញ្ញតា) ។ លក្ខណរូប៤ រូបស្សឧបចយោ រូបស្សសន្តតិ រូបស្សជរតា, រូបស្សអនិច្ចតា ត្រូវជារូបធម៌ ២៨ ។

ឯអរូបធម៌(នាមធម៌) ៥៣ នោះគឺ ចិត្ត១ (ចិត្តពិស្តារ ៨៩, ក្នុងទីនេះលើកលោកុត្តរចេញ) ចេតសិក ៥២, ត្រូវជា ៥៣ ។

រូបធម៌និងអរូបធម៌ទាំងអស់នេះ សុទ្ធតែកើតមកដោយសារអាស្រ័យកម្ម-អវិជ្ជា-តណ្ហា- (ជាហេតុ) និងអាហារជាផល ។ សេចក្តីប្រៀបធៀបដូចតទៅនេះ: ( រូបធម៌ រូបក្ខន្ធ ) កើតមកអំពីកម្មជាកុសលនិង អកុសល, ដោយកម្មនេះលោកទុកដូចជាបិតា ព្រោះមាននាទីជាអ្នកបង្កើត, អវិជ្ជា តណ្ហា ឧបាទាន លោកទុកដូចជាមាតា ព្រោះមាននាទីជាអ្នកបង្កើតផលជាអ្នកទទួលបន្ទុកជាតិកំណើតផង, អាហារ(កពឡិង្ការាហារ) លោកទុកដូចជាស្រីមេនំ ព្រោះមាននាទីជាអ្នកបីបមថ្នមបញ្ចុកនំចំណី ។

ឯអរូបធម៌ (អរូបក្ខន្ធ ៤) ក៏កើតមកអំពីកម្ម- អវិជ្ជា, តណ្ហា .

ឧបាទាន. ( ជាហេតុ ) និងអាហារជាផលដែរ. ប៉ុន្តែចំពោះអរូបក្ខន្ធគឺ វេទនាក្ខន្ធ១ សញ្ញាក្ខន្ធ១ សង្ខារក្ខន្ធ១ ត្រូវបញ្ចូលផស្សៈ(ផស្សាហារ) ជំនួសអាហារ. ដោយដកអាហារចេញ ; ឯវិញ្ញាណក្ខន្ធត្រូវបញ្ចូលនាមរូប < វិញ្ញាណាហារ > ជំនួសផស្សៈ ដោយដកផស្សៈចេញ ។ រូបធម៌និងអរូបធម៌នេះ បើរលត់លែងកើតទៀតលុះតែរលត់អស់ កម្ម.អវិជ្ជា.តណ្ហា. ឧបាទាន.អាហារ. នោះទើបមិនកើតទៀត បើធម្មសមុដ្ឋានទាំងនេះណាមួយមិនទាន់រលត់ទេ នោះសន្តតិក្ខន្ធរបស់សត្វក៏នៅតែកើតមាន ។

ដូច្នេះយោគី ត្រូវពិចារណាថា រូបក្ខន្ធកើតឡើង ព្រោះអាស្រ័យកម្ម១ អវិជ្ជា១ តណ្ហា១ ឧបាទាន១ អាហារ១ លុះតែរលត់ ធម៌ទាំង៥ ខាងលើនេះ ទើបរូបលែងកើត (កើត៥ រលត់៥ ជា១០ ក្នុងរូបក្ខន្ធ) ។

ចាត់ក្នុងអរូបក្ខន្ធ៤ ខាងចុងក៏ដូចក្នុងរូបក្ខន្ធដែរគឺ កើត៥ រលត់៥ គ្រប់ខន្ធទាំងអស់ ត្រូវជា៥០គត់ ។

ហេតុនោះបណ្ឌិតត្រូវដឹងថា រូបារូបធម៌ក្នុងទីនេះប្រព្រឹត្តទៅតែក្នុងភូមិ ៣ ទេគឺ កាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ ។

មានសេចក្តីឧបមាថា កម្ម(១) នេះលោកទុកដូចជាថ្នាល ឬស្រែ . សម្រាប់បណ្តុះពូជគឺបដិសន្ធិវិញ្ញាណ(២)នៃសត្វ. អវិជ្ជា(៣)លោកទុកដូចជាទំនប់ ឬភ្លឺស្រែសម្រាប់ឃាំងទឹកគឺតណ្ហា(៤). កុំឱ្យហូរចេញរីងអស់ពីស្រែគឺកម្ម. កាលបើទឹកគឺតណ្ហាមិនទាន់រីងអស់គឺហូរចេញពីស្រែមិនរួច ដោយជាប់ទើសទាក់និងភ្លឺ ឬទំនុបរបស់អវិជ្ជា.ស្រែកម្មក៏នៅតែមានអានុភាពតាក់តែងចាត់ចែងផ្សំ ឬបណ្តុះពូជគឺបដិសន្ធិវិញ្ញាណឱ្យចេះតែដុះទ្រុបទ្រុលមាន

(១) កម្មំខេត្តំ ។ (២) វិញ្ញាណំ ពីជំ ។ (៣) អវិជ្ជា មរិតាទំ ។ (៤) តណ្ហា សិនេហំ ។

ថ្ងៃ.ផ្កា.ស្លាប់.កើតនៅក្នុងស្រែកម្ម ទឹកតណ្ហា ទំនុបរបស់អវិជ្ជានោះជាអាហារប្បច្ច័យដល់សង្ខារតៗ ទៅ ។

ឯសង្ខារក៏ចេះតែមានកម្លាំងកសាងអត្តភាព ដឹកនាំបណ្ដើរបន្តជាតិឱ្យកើតស្លាប់អន្ទោលទៅក្នុងត្រៃលោកវិលវល់ សារចុះសារឡើងក្នុងវដ្ដសង្សាររកទីបំផុតគ្មាន ។

ចុះធម្មជាតិអ្វី ដែលបង្វិលសត្វឱ្យវិលអន្ទោលចុះឡើង ក្នុងត្រៃលោក? វដ្ដទាំង៣ ដែលជាកង់របស់ភពបង្វិលសត្វឱ្យវិលអន្ទោលសារចុះ.ឡើងមិនឈប់ឈរក្នុត្រៃលោក ! ។ ចុះវដ្ដទាំង ៣ គឺអ្វីខ្លះ ?? ។

វដ្ដទាំង ៣ នោះគឺ សង្ខារនិងភពហៅថាកម្មវដ ១. អវិជ្ជា. តណ្ហា. ឧបាទាន. ហៅថាកិលេសវដ្ដ ១. វិញ្ញាណ. នាមរូប. សឡាយតនៈ. ផស្ស. វេទនា. ហៅថាវិបាកវដ្ដ ១ ត្រូវជាវដ្ដ ៣ ។

សេចក្ដីថា : សត្វទាំងឡាយ តែងវិលស្លាប់.កើតសារចុះសារឡើង ផ្លាស់ប្ដូររូបរាងកាយ ទីឋាននិវាសចាកគ្នីគ្នា ឥតឈប់ឈរតាមយថាកម្ម << កម្មវដ្ដ >> យថាផល << វិបាកវដ្ដ >> នោះអាស្រ័យតែដោយសេចក្ដីភ័ន្តច្រឡំ << កិលេសវដ្ដ >> ដែលមានអវិជ្ជា. តណ្ហា ជាមូល.ហេតុនោះ ។ បើសេចក្ដីភ័ន្តច្រឡំ ( កិលេសវដ្ដ ) អស់ហើយ ហេតុ.ផល ( កម្មវដ្ដ និងវិបាកវដ្ដ ) ក៏មិនមាន បើហេតុ.ផលមិនមាន តើកិលេសមានមកអំពីណា ?? ។

ដូច្នេះ ការវិលអន្ទោលទៅក្នុងត្រៃលោកនៃសត្តនិករ ផ្លាស់ប្ដូររូបរាងកាយ ទីឋាននិវាសចាកញាតិមិត្ត សព្វវត្ថុសារពើ អាស្រ័យមកពីវដ្ដទាំង ៣ ណាមួយនោះឯង ។

( អភិកសង្ខារ ចប់ )

៣. **អភិសង្ខរណកសង្ខារ ( តេត្ថចិកកុសលាកុសលចេតនា ឥទំ អភិសង្ខរណកសំខារោតិ វុច្ចតិ )** កុសលចេតនា និងអកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិទាំង៣ លោកហៅថា**អភិសង្ខរណកសង្ខារ** ។

អភិសង្ខរណកសង្ខារនោះ បើនិយាយតាមអាគតដ្ឋានវាប្រាកដដូច ទ្ធដីកាថា: **អវិជ្ជា តិក្ខវេ អវិជ្ជាគតោ បុញ្ញាភិសំខារញ្ចេ អភិសង្ខរោតិ អបុញ្ញាភិសំខារញ្ចេ អភិសង្ខរោតិ អានេញ្ជាភិសំខារញ្ចេ អភិសង្ខរោតិ...**។

ម្នាលភិក្ខុទាំងឡាយ បុរសស្ត្រីក្នុងលោក ដែលតាំងខ្លួនក្នុងអវិជ្ជានៅ ឡើយគេតែងតែធ្វើ ឬកសាងនូវបុណ្យ-បាប ឬអានេញ្ជាភិសង្ខារសំណាង បស់ខ្លួន បានល្អខ្លះអាក្រក់ខ្លះ ឥតដឹងចតុរារិយសច្ចទេ ដូចមនុស្សខ្វាក់វា តងតែដើរខុសផ្លូវខ្លះ ត្រូវផ្លូវខ្លះ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា សលាកុសលចេតនាដែលជាឈ្មោះរបស់អភិសង្ខារណកសង្ខារនោះជាប់ ាក់ទងដោយអវិជ្ជានៅឡើយ ។ លុះតែកុសលចេតនាណាដែលប្រព្រឹត្ត ទ្បងផុតនូវត្រៃលោក មិនជាប់ទាក់ទងដោយអវិជ្ជា. គឺថាអវិជ្ជាគេក៏លះ ង់បានហើយ ទស្សនវិជ្ជាក៏កើតឡើង ទើបអំពើនោះល្អបរិសុទ្ធគ្មាន ណ្យ-បាប បរិសុទ្ធដោយចំណែកមួយជាវិសង្ខារ ។

តាមន័យនេះ បើមានអវិជ្ជាទើបមានសង្ខារ មានបុញ្ញាភិសង្ខារជាអាទិ៍. បីសង្ខារមិនមានអវិជ្ជាក៏មិនមានដែរ ។

ត្រង់ពាក្យថា: បើសង្ខារមិនមានអវិជ្ជាក៏មិនមាននោះ លុះតែបុគ្គលនោះ ានសម្រេចនូវមគ្គ-ផលគឺព្រះនិព្វាន ។

ឯមនុស្សទេវតាក្នុងត្រៃលោក ដែលកំពុងត្រេចរង្គាត់ក្នុងវដ្តសង្សារនៅ ឡើយនោះ សុទ្ធតែនៅក្នុងអានុភាពនៃសង្ខារដែលមានអវិជ្ជាជាបច្ច័យ ។

ត្រូវអាស្រ័យដោយឧបការបច្ច័យរបស់អវិជ្ជា ទើបចេះធ្វើ ចេះកសាង ខ្លួនឱ្យមានទស្សនវិជ្ជា ឱ្យមានសិល្បៈផ្សេងៗ ឱ្យមានអនាគតល្អ តែគង់ច្រឡំដោយបាបគ្រោះទោសកំហុសខ្លះ ព្រោះចេតនាកម្មជាតួសង្ខារនោះ ជាប់ទាក់ទងដោយឧបការបច្ច័យរបស់អវិជ្ជាលះបង់មិនទាន់អស់នៅឡើយ ។

សមដូចបទថា **ឯតំ យស្មា អវិជ្ជាភាវេ ភាវេ សង្ខារភាវោ ន អភាវេ តស្មា ជានិតព្វមេតំ ឥមេ សង្ខារា អវិជ្ជាបច្ចយា ហោន្តីតិ ។** មានសង្ខារព្រោះមានអវិជ្ជា មិនមានសង្ខារព្រោះមិនមានអវិជ្ជា ហេតុណា ហេតុនោះបណ្ឌិតត្រូវដឹង នូវព្រឹត្តិការនុ៎ះយ៉ាងនេះថា សង្ខារទាំងឡាយមាន បុញ្ញាភិសង្ខារជាអាទិ៍នេះ រមែងកើតឡើងដោយសារឧបការបច្ច័យរបស់ អវិជ្ជាជាដាច់ខាត ។

**បុច្ឆា:** អំពៅមិនដែលកើតមកពីពូជស្ពៃទេ ចុះឯអវិជ្ជានេះជាអនិដ្ឋផលប្រកបទៅដោយទោស ដោយចំណែកមួយម្ដេចក៏ជាឧបការបច្ច័យរបស់ បុញ្ញាភិសង្ខារកើត ? ។

**វិស្សជ្ជនា:** បច្ច័យរបស់សភាវធម្មជាតិទាំងឡាយក្នុងលោកគង់ជាបច្ច័យ សម្រេចខុស ចាកសភាវកិច្ច ឋានក៏មាន មិនខុសគឺត្រូវតាមសភាវ កិច្ច ឋានក៏មាន ស្មើតាមសភាវ កិច្ច ឋាន ក៏មាន មិនស្មើតាមសភាវ កិច្ច ឋាន ក៏មាន ហើយសភាវធម្មជាតិនោះមិនមែនវិបាកសម្រេចផង ។

ដូចបុរិមចិត្ត ជាបច្ច័យរបស់អបរចិត្ត (បច្ច័យខុសចាកឋាន) ទឹកដោះស្រស់ជាបច្ច័យដល់ទឹកដោះជូរ ( បច្ច័យខុសចាកសភាវៈ ) ពន្លឺជាបច្ច័យដល់ចក្ខុវិញ្ញាណ ទឹកអំពៅជាបច្ច័យដល់មេរ័យ (បច្ច័យសម្រេចខុសចាកកិច្ច)។

ចក្ខុរូបជាអាទិ៍ ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម (បច្ច័យមិនខុសចាកឋាន)

បុរិមជវនជាអាទិ៍ជាបច្ច័យដល់ជវនទាំងឡាយមានបច្ឆិមជវនជាដើម (បច្ច័យមិនខុសចាកសភាវៈកិច្ច) ។

សទិសរូបគឺ ឧតុអាហារជាបច្ច័យដល់រូប, ពូជធញ្ញជាតិមានស្រូវសាលីជាដើម ជាបច្ច័យដល់ផ្លែនៃស្រូវសាលីជាដើម (បច្ច័យស្មើតាមឋាន) ។

អសទិសរូប ជាបច្ច័យដល់អរូប, អរូបជាបច្ច័យដល់រូប (បច្ច័យមិនស្មើតាមសភាវៈកិច្ច) ។

បច្ច័យរបស់សភាវធម្មជាតិទាំងឡាយណា (សម្រេច) ខុសឬមិនខុសចាកចាកសភាវៈកិច្ចៈឋាន, ស្មើឬមិនស្មើតាមសភាវៈកិច្ចឋាន, បែបនេះបច្ច័យរបស់សភាវធម្មជាតិទាំងនោះ មិនមែនជាវិបាកនៃធម៌ទាំងនោះទេ ។ ឯអវិជ្ជានេះជាឯកន្តអនិដ្ឋផល, ដោយអនុភាពនៃវិបាកផង, ប្រកបដោយទោសតាមសភាវៈធម៌ផង, ដូច្នេះអវិជ្ជា បណ្ឌិតត្រូវតែដឹងថា: <<ជាឧបការប្បច្ច័យខុសចាកឋានៈសភាវៈកិច្ចក៏មាន, មិនខុសគឺត្រូវតាមឋានសភាវៈកិច្ចក៏មាន, និងជាបច្ច័យស្មើតាមឋានសភាវៈកិច្ចក៏មាន, មិនស្មើតាមឋានសភាវកិច្ចក៏មានដល់ សង្ខារទាំងឡាយមានបុញ្ញាភិសង្ខារជាដើមនោះតាម សមគួរដល់យថាហេតុ>>.។

ភាពនៃអវិជ្ជាជាឧបការប្បច្ច័យដល់សង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើមនោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ពន្យល់ បន្ថែមយ៉ាងនេះថា:

<<អវិជ្ជាគឺធម្មជាតិ ដែលមិនដឹងច្បាស់ នូវចតុរារិយសច្ចនិងធម្មជាតិ>> តែងបញ្ជូនសត្វឱ្យទៅកើត នៅត្រឹមតែកំណើតទាំង៤, គតិទាំង៥, ភព៣, វិញ្ញាណដ្ឋិតិ៧, សត្តាវាស៩, គ្មានទីបំផុតតែប៉ុណ្ណោះ ។ បុគ្គលណាមិនទាន់លះបង់បានទេ បុគ្គលនោះរមែងតែប្រកាន់យកនូវសង្សារទុក្ខ ថាជាសេចក្តីសុខ ព្រោះការមិនដឹងច្បាស់នូវចតុរារិយសច្ចនោះជាបឋម ។

ហើយបបួលគ្នាប្រារព្ធធ្វើតែសង្ខារទាំង៣ មានបុញ្ញាភិសង្ខារជាដើម

ដែលជាមូលហេតុនៃសង្សារទុក្ខក្នុងវដ្តសង្សារគឺត្រៃលោកទាំង៣ នោះឯង ។

ម្យ៉ាងទៀតអវិជ្ជានេះមាន៣ គឺៈ អញ្ញាណៈ១ អទស្សនៈ១ មោហៈ១។ អញ្ញាណនោះមាន៨គឺៈ ១. **ទុក្ខេ អញ្ញាណៈ** <ការមិនដឹងក្នុងទុក្ខសច្ច>, ២.**ទុក្ខសមុទយេអញ្ញាណៈ**<ការមិនដឹងក្នុងទុក្ខសមុទយសច្ច>,៣.**ទុក្ខនិរោធេ អញ្ញាណៈ**<ការមិនដឹងក្នុងទុក្ខនិរោធសច្ច>,៤. **ទុក្ខនិរោធគាមិនី បដិបទាយ អញ្ញាណៈ** (ការមិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា). ៥.**បុព្វន្តេ អញ្ញាណៈ** (ការមិនដឹងនូវខន្ធបញ្ចកៈក្នុងអតីតទ្ធា) ;៦. **អបរន្តេ អញ្ញាណៈ** (ការមិនដឹងនូវខន្ធបញ្ចកៈក្នុងអនាគតទ្ធា) ; ៧. **បុព្វន្តាបរន្តេអញ្ញាណៈ** "ការមិនដឹងនូវប្រជុំពីរនៃអទ្ធាទាំងពីរនោះ > ៨.**សបដិច្ចសមុប្បាទេ អញ្ញាណៈ** (ការមិនដឹងក្នុងបដិច្ចសមុប្បាទ) ។ ឯអទស្សនៈនោះមានពីរគឺៈ ១.គ្មានទស្សនវិជ្ជាក្នុងវិជ្ជា៣ ។ ២. គ្មានទស្សនៈវិជ្ជាក្នុងវិជ្ជា៨ ។ ចំណែកមោហៈនោះមាន៥ គឺៈ ( **ចតូបធាតេ សំសារេ សង្ខារានញ្ច លក្ខណេ យោ**

**បដិច្ចសមុប្បន្នេ ធម្មេសុ ច មិច្ឆាយុត្តិ** ) ។

១. នរជនណា វង្វេងគឺការភន្តច្រឡំក្នុងចុតិ . គឺមិនកាន់យកនូវការច្យុត <បានដល់ការបែកធ្លាយរបស់ខន្ធទាំងឡាយក្នុងភពទាំងអស់> ថាជាមរណៈទៅជាយល់ខុសថា ការយាងចុះកាន់អន្តរអត្តភាពរបស់សត្វ ទើបសត្វស្លាប់ទៅវិញក្តី ។

២. វង្វេងក្នុងការកើត. គឺមិនកាន់យកនូវការកើត<បានដល់ធាតុភាពរបស់ខន្ធទាំងឡាយ ក្នុងភពទាំងអស់> ថាជាជាតិ. បែជាយល់ខុសថាធាតុភាពរបស់សរីរៈថ្មីរបស់សត្វកើតឡើងវិញក្តី ។

៣. វង្វេងក្នុសង្សារ .តំណតភ្ជាប់របស់ខន្ធនិងធាតុ អាយតនៈទាំងឡាយ

ដែលប្រព្រឹត្តជាប់តគ្នាជាប់មិនដាច់ លោកហៅថាសង្សារ. ខ្លួនមិនកាន់យកនូវសភាពបែបនោះហៅថាសង្សារ. ទៅជាយល់ខុសថា សត្វទៅអំពីលោកនេះទៅកាន់បរលោក មកអំពីបរលោក មកកាន់លោកនេះទៅវិញក្តី ។

៤. វង្វេងក្នុងលក្ខណរបស់សង្ខារ. គឺមិនកាន់យកនូវសង្ខារធម៌ទាំងឡាយថា ជាសភាវលក្ខណៈ. ឬសាមញ្ញលក្ខណៈ ទៅជាយល់ខុសថាៈ សង្ខារធម៌ទាំងឡាយជារបស់ខ្លួន. ជារបស់តាំងនៅក្នុងខ្លួន ជារបស់ទៀងជារបស់ល្អ ជារបស់សុខស្រួលទៅវិញក្តី ។

៥. វង្វេងក្នុងបដិច្ចសមុប្បន្នធម៌. គឺមិនកាន់យកនូវប្រវត្តិនៃសង្ខារធម៌ទាំងឡាយដែលប្រព្រឹត្តមកអំពីបច្ច័យទាំងឡាយមានអវិជ្ជាជាដើម. ទៅជាយល់ខុសថាការចេះ ឬមិនចេះក្តីស្រេចតែខ្លួនអញវិញ. ខ្លួនអញហ្នឹងឯងធ្វើក៍បានប្រើនរណាឱ្យធ្វើក៍បាន. ខ្លួនអញបង្កើតខ្លួនអញ <មនុស្សបង្កើតមនុស្ស> ព្រះឥស្វរឬព្រះអាទិទេព តែងជួយអប់រំសិរីៈខ្លួនអញ តាំងពីកលលៈរូបមក ជួយបំពេញបំប៉នឥន្ទ្រីយ៍ឱ្យអញ. ខ្លួនអញបរិបូណ៌ដោយឥន្ទ្រីយ៍. ហើយរមែងតែពាល់ត្រូវ.ទទួលរង.ទទួលយក.ប្រកាន់ខ្ជាប់.ប៉ះទង្គិច< ដោយឯងៗ > ខ្លួនអញរមែងតែកើតមានក្នុងអន្តរភពទៀត.ឬយល់ខុសថា សព្វសត្វទាំងអស់មានសភាពឱនទៅកាន់និយតិភាពនិងសង្គតិភាពក្តី ។

ជាពិសេសពួកមោហ៍មូហជនទាំងនោះតែងយល់ច្រឡំទៀតដែរគឺៈ

១.ភន្ត័ច្រឡំពូជ.២.ភន្ត័ច្រឡំទឹកស្រមុទ្រ(ភូមិសាស្ត្រ):៣.ភន្ត័ច្រឡំកំណើត ។

ក. ឯការ**ភាន្តច្រឡំពូជ**នោះពួកគេតែងនិយាយថា.

**<ព្រាហ្មណា(១) ព្រហ្មុនា មុខតោ និព្វត្តា. ខត្តិយា ឧរតោ.**

(១) មជ្ឈិមនិកាយបញ្ចកបាយអារតជូនិយសូត្រ

**វេស្សា នាភិតោ, សុទ្ទា ជាណុតោ, សមណា បិដ្ឋិបាទតោតិ** > ២
ពួជព្រាហ្មណ៍ទាំងឡាយកើតមកអំពីមាត់មហាព្រហ្ម. ពួជក្សត្រទាំងឡាយកើតមកអំពីទ្រូងមហាព្រហ្ម. ពួជអ្នកជួញទាំងឡាយកើតមកអំពីរន្ធផ្ចិតមហាព្រហ្ម.ពួជអ្នកស្រូទ្រៈ គឺកម្មករកសិករទាំងឡាយកើតមកអំពីស្នងមហាព្រហ្ម. ពួកសមណៈទាំងឡាយកើតមកអំពីបាទជើងមហាព្រហ្ម >គេពោលចែកពូជនេះដើម្បីអ្វី ? ដើម្បីវាយតម្លៃពួកគេទាំងពីរវណ្ណៈ ខាងដើមនោះឱ្យខ្ពស់ដល់មេឃ ដោយចង់សំឡុតវណ្ណៈ ៣ ខាងចុងឱ្យគោរពលុតក្រាបក្រោមល្អងធូលីព្រះបាទរបស់គេ. រួចឱ្យវណ្ណៈ ៣ នេះរកសួយអាករជាតិចូកល់អាថ៌កំបាំងដ៏លាមកមួយហៅថា <<**យញ្ញពិធី**>> ដើម្បីបោកបញ្ឆោតនិងបំពេញតណ្ហាគេ និងជួយលើកតម្កើងពួកគេ. រួចបំភន្តអ្នកដែលខ្លាចញ័រសាច់ទៅហើយនោះថា: ពួកគេសុទ្ធតែជាពូជអាទិទេព ទើបនិងច្យុតចុះមកពីទេវព្រហ្ម. ពួកគេជាអ្នកបានទទួលឱវាទផ្ទាល់មាត់ផ្ទាល់បេះដូងពីព្រះព្រហ្មមក ព្រះព្រហ្មទ្រង់បញ្ជូនពួកគេ ឱ្យមកប្រដៅត្រួតត្រាជិះជាន់មនុស្សលោក ។ ពួកនេះវាមិនត្រឹមតែបន្ទុះបង្គាប់អ្នកដទៃ រួចលើកកំពស់ពួកវាប៉ុណ្ណោះទេ. គេថែមទាំងតែងតាំងស្ថានព្រហ្មលោកនោះ ថាជា<<**និព្វានដ្ឋាន**>>របស់ឪគេដែរ.. ដូច្នេះបានជាលទ្ធិសាសនាដ៏ចាស់គំរិលរបស់គេមាននាមបញ្ញត្តិថា:<<**ព្រហ្មញ្ញសាសនា**>>នោះ ។ មកពីពួកទាំងនោះលង់គំនិតដោយសារបបញ្ចធម៌៣ យ៉ាងគឺ:មានៈ១ ទិដ្ឋិ១តណ្ហា១ នោះឯង បានជាពួកនេះខូចសតិក្លាយជាអ្នក. អត្តានិយមជ្រុល.នោះ ។

ខ. ការ **ភន្តច្រឡំទឹកសមុទ្រ:**សេចក្តី(១)ដំណាលថាថ្ងៃមួយមាន[illegible]

(១) បាកភូវិទក្ខជាតកវណ្ណនា: ។

ពួកព្រាហ្មណ៍ម្នាក់កំពុងងូតទឹកលាងបាប ហើយឈរនៅក្បែរមាត់ច្រាំងគេយក ទឹកពីសមុទ្រ មកលាបស្រឡាបហើយព្រោះព្រំលើខ្លួនគេ ។ ស្រាប់តែពេល នោះ ទឹកសមុទ្រក៏ជោរឡើង អូសទាញគេពន្លិចស្លាប់ ក្នុងសមុទ្រនោះទៅ មហាព្រហ្មបានឮពត៌មានថា ទឹកសមុទ្រសម្លាប់កូនគេ ដូច្នេះហើយក៏ដាក់ បណ្តាសាថា សូមឱ្យទឹកសមុទ្រឯងប្រែរហូតកុំឱ្យអ្នកណាផឹកកើត។ ដោយហេ នោះឯងទើបទឹកសមុទ្រប្រៃផឹកមិនកើតរហូតដល់បច្ចុប្បន្ននេះ ។

គ. **ការភន្តច្រឡំកំណើត** ពួកព្រាហ្មណ៍តែងនិយាយថា: ព្រះបរមេសូរ(១) បណ្តាលឱ្យព្រះព្រហ្មកើតក្នុងស៊ុត រួចស៊ុតនោះបែកចេញជាពីរភាគ គឺភាគខាង លើកើតជាមេឃភាគខាងក្រោមកើតជាមនុស្សលោក ។

ម៉្យាងទៀតថា: ព្រះមង្គល. ព្រះមន្ត.ព្រះវេទ. ប្រជុំគ្នាបង្កើតជាព្រះឥសូរ ឯព្រះឥសូរបង្កើតនាងឧមាភគវតី. ព្រះឥសូរនិងនាងឧមាភគវតីបង្កើតព្រះ នារាយណ៍និងព្រះព្រហ្មធាតា រួចទើបគេនាំគ្នាបង្កើតមេឃ អាកាស ទឹកដី មនុស្សសត្វ នឹងថ្ងៃ ខែ ឆ្នាំ ឡើងទៀត ។

**អភិសង្ខរោតិ សោ ឯតេ សង្ខារេ តិវិធេ យតោ**

**អវិជ្ជាបច្ចយា តេសំ តិវិធានមយំ តតោ ។**

ពួកនរជនទាំងនោះគឺអវិជ្ជាធ្វើឱ្យងងឹតងងល់យ៉ាងនេះហើយរមែងយល់ ខុសជាត្រូវដូចមនុស្សខ្វាក់ដើរខុសផ្លូវខ្លះត្រូវផ្លូវខ្លះ. តែងប្រមូលគ្នាធ្វើបូកសាង នូវសំណាងតែ៣ ហ្នឹងគឺបុញ្ញាភិសង្ខារ១.អបុញ្ញាភិសង្ខារ១.អានេញ្ជាភិសង្ខារ គឺបុណ្យខ្លះ បាបខ្លះ ត្រូវខ្លះ ខុសខ្លះ ដែលជាមូលហេតុ នៃសង្សារទុក្ខ. សុខដែរ តែជាសាមិសសុខក្នុងត្រៃលោក. ព្រោះហេតុណាហេតុនោះ អវិជ្ជ ក៏ចេះតែជួយជាបច្ច័យ ដល់សង្ខារទាំង ៣ នេះឥតឈប់ឈរដែរ ។

(១) បាកគម្ពីរត្រៃវេទ ។

**យទា ច ញត្វា សោ ធម្មំ សច្ចានិ អភិសមេស្សតិ**

**តទា អវិជ្ជូបសមា ឧបសន្តោ ចរិស្សតិ ។**

បើពេលណានរជននោះ បានដឹងច្បាស់នូវធម្មាភិសម័យហើយត្រាស់ដឹងនូវអរិយសច្ចទាំង ៤. ពេលនោះខ្លួននិងបានលុះនូវឧបសន្តធម៌ <<**និព្វាន**>> ព្រោះការស្ងប់រំងាប់ទៅនៃអវិជ្ជា. ( សកម្មភាពរបស់អវិជ្ជាក៏ចប់ត្រឹមនេះអស់មានបុណ្យបាប សុខទុក្ខដ៏ច្របូកច្របល់យ៉ាងនេះទាំងជាតិ ជរា ក៏អស់មានទៀត មានតែសុខដ៏ឯកហៅថាឯកន្តបរមសុខឬនិរាមិសសុខ ) ។

**សច្ចំ សត្តោ បដិសន្ធិ បច្ចយាការតាបិ ច**

**ទុទ្ទសា ចតុរោ ធម្មា ទេសេតុញ្ច សុទុក្ករា ។**

ធម៌ដែលគេមិនងាយយល់ និងមិនងាយសំដែងមាន ៤ គឺៈ ១.ចតុរារិយ.សច្ច. ២.សត្តវិញ្ញាណ. ៣.សត្តបដិសន្ធិ. ៤.បដិច្ចសមុប្បាទ ។

( អភិសង្ខរណកសំខារ ចប់ )

## ៤. បយោគាភិសង្ខារ

**កាយិកចេតសិកំ បន វីរិយំ បយោគាភិសំខារោតិ វុច្ចតិ ។**

សេចក្ដីព្យាយាមដែលអាស្រ័យឬកើតក្នុងកាយនិងចិត្តលោកហៅថា បយោគាភិសង្ខារ ។

**សោ យាវតិកា អភិសំខារស្ស គតិ តាវតិកំ គន្ត្វា អក្ខាហតំ មញ្ញេ អដ្ឋាសីតិ អាទីសុ អាគតោ ។ ន កេវលញ្ហ ឯតេយេវ អញ្ញេ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស ខោ អាវុសោ វិសាខ ភិក្ខុនោ បឋមំ និរុជ្ឈតិ វចីសំខារោ តតោ កាយសំខារោ តតោ ចិត្តសំខារោតិ អាទិនានយេន សំខារសទ្ទេន អាគតា អនេកសំខារា ។**

បយោគាភិសង្ខារនោះវាមានអាគតដ្ឋានចំហាយទៅក្នុងបយោគទាំងឡាយជាច្រើនមានថើមថា គតិរបស់អភិសង្ខារដើរទៅអស់រយៈកាលត្រឹមណា. បយោគវាក៏ដើរទៅហើយឈប់ដូចជារថចក្រពាក់ភ្លៅនៅត្រឹមនោះដែរ ។

មិនត្រឹមតែសង្ខារនុ៎ះប៉ុណ្ណោះទេ. សូម្បីសំខារឯទៀតជាអនេកក៏ចំហាយចេញមកតាមសម្លេងសំខារ ដោយន័យជាអាទិ៍ថាៈហៃអាវុសោវិសាខ! កាលភិក្ខុកំពុងចូលសញ្ញា(១) វេទយិតនិរោធ វចីសង្ខាររលត់មុន. បន្ទាប់ពីនោះមកទើបកាយសង្ខាររលត់. បន្ទាប់ពីនោះមកទៀត ទើបចិត្តសង្ខាររលត់ក្រោយបំផុតដែរ ។

**តេសុ នត្ថិ សោ សំខារោ យោ សំខតសំខារេ សង្គហំ ន គច្ឆេយ្យ ។**

បណ្តាសង្ខារទាំងនោះ មិនមានសង្ខារណាមួយដែលមិនសង្គ្រោះចូលក្នុងសំខតសង្ខារនោះឡើយ ។

ការផ្សំប្រកប. ការប្រឹងប្រែង. សេចក្តីព្យាយាម. ហៅថាបយោគៈ។ ការធ្វើផ្ទាល់ខ្លួន. ការកសាងនូវសំណាងផ្ទាល់ខ្លួន. ហៅថាអភិសង្ខារ ។

រួមជាបទសម្ពន្ធហៅថាបយោគាភិសង្ខារ. ប្រែថាសំណាងកើតមកពីព្យាយាម. ឬព្យាយាមកសាងនូវសំណាងផ្ទាល់ខ្លួន ។

ឧទាហរណ៍: (បុញ្ញាភិសង្ខារម្បិ អបុញ្ញាភិសង្ខារម្បិ អភិសង្ខរោតិ) គេកំពុងព្យាយាមធ្វើឬកំពុងព្យាយាមកសាងនូវអំពើបុណ្យ.បាប. ល្អ.អាក្រក់ផ្ទាល់ខ្លួនគេជាហេតុ ។

(១)អ្នកចូលសញ្ញាវេទយិតនិរោធសង្ខារទាំង៣ រលត់មែន ប៉ុន្តែអាយុមិនអស់. ឧស្មន(តេជោធាតុ)មិនរលត់.ឥន្ទ្រិយ៍(បសាទរូប)ទាំង៥ណាមួយមិនខូច.ដូច្នេះទើបគេមិនស្លាប់ ។ ឯអ្នកស្លាប់សង្ខារទាំង៣ក៏រលត់.អាយុក៏អស់.តេជោធាតុក៏រលត់.ឥន្ទ្រីទាំង៥ណាមួយក៏ខូចប្រើការមិនកើត.ដូច្នេះទើបគេមិនស្លាប់. ( មជ្ឈិមនិកាយយម្ពកថាយចុល្លវេទល្លសុត្ត ) ។

*នារីថ្នាំសមុទ្រឈ្មោះមណីមេខលា និយាយបន្ទះមហាជនថា:*

**គម្ភីរេ អប្បមេយ្យស្មឹ តីរំ យស្ស ន ទិស្សតិ**

**មោឃោ តេ បុរិសវាយាមោ អប្បត្វា វ មរិស្សតីតិ**

ត្រើយសមុទ្រដ៏ឆ្ងាយឥតគណនា មិនប្រាកដដល់អ្នកណា. បុរសព្យា-យាមរបស់អ្នកនោះ. វាគ្មានប្រយោជន៍អ្វីទេ. អ្នកខំព្យាយាមហែលក៏វាមិនដល់ដែរ ហើយអ្នកនឹងស្លាប់មិនខាន ។

*មហាជនក៏ឆ្លើយបំភ្លឺថា:*

**អនណោ ញាតិនំ ហោតិ ទេវានំ បិតុនញ្ច**

**សោ ករំ បុរិសកិច្ចានុតប្បតីតិ ។**

គេធ្វើព្យាយាមបើទុកជាស្លាប់ ក៏គេមិនក្តៅក្រហាយស្តាយក្រោយដែរ. គេថែមទាំងគ្មានក្តីតិះដៀលអំពីសង្គមញាតិ.ទេវតានិងពួកព្រហ្មទៀតផង ។ កាលមហាជនបានទទួលរាជសម្បត្តិហើយ លោកនឹកឃើញនូវវិរិយបារមីនោះ លោកក៏បន្លឺឧទានវាចាថា: ។

**អាសិសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**

**បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុំ ។**

បុរសស្ត្រីជាបណ្ឌិតត្រូវតែប៉ងប្រាថ្នា. ត្រូវតែខំព្យាយាមកុំរួញរា. យើងគង់តែឃើញនូវខ្លួនវិញ. យើងប៉ងយ៉ាងណា. យើងគង់តែបានយ៉ាងនោះពុំខាន ។

**វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**

**បស្សាមិ វោហំ អត្តានំ យថា ឥច្ឆិ តថា អហុំ ។**

បុរសស្ត្រីជាបណ្ឌិតត្រូវតែខំព្យាយាម. មិនត្រូវខ្ជិលច្រអូសឡើយ. យើងគង់ឃើញនូវខ្លួនយើងវិញ.យើងប្រាថ្នាបែបណា.គង់តែបានបែបនោះវិញមិនខាន។

**ទុក្ខូបនីតោបិ នរោសបញ្ញោ អាសំ ន ឆិន្ទេយ្យ សុខាគមាយ**

**ពហូ ហិ ផស្សា អហិតា ហិតា ច អវិតក្កិតារោ មច្ចុមុបព្ពជន្តិ**

បើម្បីដល់នូវក្តីសុខអ្នកមានប្រាជ្ញាសូម្បីក្តីទុក្ខកំពុងគ្របសង្កត់ក្តី ក៏គេមិនត្រូវលះបង់នូវសេចក្តីបំណងចោលឡើយ. ផស្សៈទាំងឡាយជាចំនួនច្រើនគឺៈ ទុក្ខសម្ផស្សៈ ជាអហេតុកម្ម. និងសុខសម្ផស្សៈជាអហេតុកម្ម. តាមពិតគេមិនគិតក៏គង់តែស្លាប់ ។

**អចិន្តិតម្បិ ភវតិ ចិន្តិតម្បិវិនស្សតិ នហិ**

**ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្សវាតិ ៕**

(ជួនណា) ហេតុការណ៍ណាដែលគេមិនគិត បែរជាកើត. ហេតុណាដែលគេគិតវាបែរជា (មិនកើត) សូន្យ. តាមពិតភោគទាំងឡាយរបស់បុរសស្ត្រីវាមិនសម្រេចតាមគំនិតដែលគិតឡើយ ។

**តស្មា វីរិយន្ទាម ភតព្វមេវ**

ព្រោះហេតុនោះគេត្រូវតែខំព្យាយាមធ្វើកុំខាន ។

**និទ្ទា តន្ទី វិជិម្ភិតា អរតិ ភត្តសម្មទោ**

**អាវសនន្តិ សរីរដ្ឋា ពហូ ហិ បរិបន្ថយោតិ ៕**

ប្រភពនៃអន្តរាយគឺក្តីខ្ជិលដែលពួនក្នុងសរីរៈ មានបែបច្រើនណាស់គឺៈ ១. **និទ្ទា** (ដោកងក់មមី) ; ២. **តន្ទី** (ស្ពឹកឬខ្ជិលទំនេ) ៣. **វិជិម្ភិតា**, ជុំទើតជុំទាស់កាយ ) ៤. **អរតី** ( អប្សុកអប្សាន្តមិនរីករាយ ). ៥. **ភត្តសម្មទោ** ( ស្រវឹង ឬ ពុលបាយ ) ។

### អាចារ្យសេនកថា:

ធិរា ច ពាលា ច ហវេ ជនិន្ទ សិប្បូបបន្នា ច អសិប្បិនោ

ច សុជាតិមន្តោបិ អជាតិមស្ស យសស្សិនោ បេស្សករា ភវន្តិ

ឯតម្បិ ទិស្វាន អហំ វទាមិ បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រអ្នកធំ! ជនានុជនទាំងឡាយទោះជាអ្នកប្រាជ្ញឬល្ងង់ខ្លៅក្តី. មានសិល្ប.ក្តី. មានជាតិខ្ពង់ខ្ពស់ ឬមិនមានជាតិខ្ពង់ខ្ពស់ក្តី. ក៏គង់តែជាអ្នកបំរើអ្នកមាន.សិរីយសគឺ: អ្នកមានភោគមិនខាន. ខ្ញុំឃើញនូវហេតុនោះទើបនិយាយថា: អ្នកមានប្រាជ្ញាអន់បំផុត. អ្នកមានភោគ:យសសក្តិ ទើបប្រសើរ ។

### មហោសថបណ្ឌិតថា:

បាបានិ កម្មានិ ករោតិ ពាលោ ឥធមេវ សេយ្យោឥតិ មញ្ញមានោ

ឥធលោកនស្ស បរលោកំ អនស្ស ឧភយត្ថ ពាលោ កលិមគ្គហេសិ

ឯតម្បិ ទិស្វាន អហំ វទាមិ បញ្ញោវ សេយ្យោ ន យសស្សិពាលោតិ ។

ជនពាលតែងធ្វើអំពើអាក្រក់មិនស្រាក. ជនពាលតែងយកឥស្សរិយភាពជាកំពស់ក្នុងលោកនេះ. ជនពាលមើលឃើញកាលខ្ចីតែក្នុងលោកនេះ. ជនពាលមើលមិនឃើញសត្វដ៏ទៃទេ. ជនពាលកាន់យកខុសក្នុងលោកទាំងពីរ.ខ្ញុំឃើញនូវហេតុការនុ៎ះ ទើបនិយាយថា: ជនអ្នកមានប្រាជ្ញាថ្លៃថ្លាបំផុត.ឯជនពាលមានភោគ: យសសក្តិ ឥតតម្លៃឡើយ ។

( បយោគាភិសង្ខារ ចប់ )

<< សំខារបរិយាយ ចប់ត្រឹមបុណ្ណោះឯងហោង >>

***************************************

**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា**
**អាចរិយូបការា ច មាតាបិតា បិយា មមំ**
**សុរិយោ ចន្ទិមា រាជា គុណវន្តា នរា បិច**
**ព្រហ្មា មារា ច ឥន្ទា ច លោកបាលា ច ទេវតា**
**យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកា បិច**
**សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ**
**សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោ មតំ ៕**

ប្រែ ដោយអំពើរបុណ្យ សោភ័ណនេះណា សូមសព្វសត្វា
មាននាមត៏ទៅ ឧបជ្ឈាយាចារ្យ ជូនតាមែឪ
គុណធ្ងន់ពេកក្រៃ ជាម្លប់នៃខ្ញុំ ។ សុរិយាចន្ទ្រា
ប្រជាតូចធំ ជនក្នុងសង្គម មានគុណចាំថែ
ពួកព្រហ្មពួកមារ ឥន្ទ្រាផងដែរ ទេវតាចាំថែរ
នាមលោកបាល ។ យោមរាជមិត្តភ័ក្តិ ភ្ញើម្រាក់ត្រកាល
មនុស្សចិត្តកណ្តាល នឹងអ្នកចងពៀរ ។ សូមបានក្តីសុខ
និរទុក្ខគ្រប់គ្នា កុំមានកម្មពៀរ សព្វគ្រាទៅចុះ
ផលបុណ្យទាំងឡាយ ដែលយើងសាងនោះ សូមឱ្យបានលុះ
សុខ ៣ ប្រការ ១ សុខនាមនុស្ស ២ នោះទេវតា
៣ សុខបរមា គឺព្រះនិព្វាន ។ សូមអស់លោកអ្នក
ចិត្តស្មើគ្រប់ប្រាណ បានផលនិព្វាន ឆាប់ ៗ ទៅហោង ។

**ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច ខិបាហំ សុលភេ**
**ចេវ តណ្ហុបាទាន ឆេទនំ យេ សន្តានេ ហីនា ធម្មា**
**យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ យត្ថ ជាតោ**
**ភវាភវេ ឧជុំចិត្តំ សតិបញ្ញា សល្លេខោ វីរិយោម្ហិ នា មារា**
**លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ ពុទ្ធា ធិបវរោ នាថោ**
**ធម្មោ នាថោ វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ**
**មមំ តេសោត្តមា នុភាវេន មារោកាសំ លភន្តុមា ៕**

ប្រែ ដោយអំពើបុណ្យ សោភ័ណទាំងនេះ នឹងការឧទ្ទិស
ដល់សព្វសត្វា ខ្ញុំគប្បីបាន កាត់ស្ពានតណ្ហា ឧបាទានា
ងាយឆាប់កុំខាន ធម៌ណាទាបថោក ជក់ជោកសណ្តាន
សូមអន្តធាន វិនាសបាត់បង់ សព្វកាលកុំខាន បានក្សាន្តមនោរម្យ
សុខសាន្តដល់ខ្ញុំ រហូតនិព្វាន ខ្ញុំកើតជាតិណា ភវាភវម្ពាន
តូចធំសូមមាន សន្តានស្មោះត្រង់ សូមមានប្រាជ្ញា ស្មារតីវយ័ខ្ជង់
ស្អាតស្អំថ្កូវផង់ ស្មោះត្រង់ព្យាយាម ពួកមារសត្រូវ សូមកុំដេញតាម
ធ្វើឱ្យរើមរាម ក្នុងព្យាយាមខ្ញុំ ព្រះពុទ្ធព្រះធម៌ បវរឧត្តម ទីជ្រកនៃខ្ញុំ
អភិរម្យដូចកោះ បច្ចេកពុទ្ធ សង្ឃសុទ្ធជាន់ខ្ពស់ ទីជ្រកខ្ញុំនោះ
ខ្ពង់ខ្ពស់បរមា ដោយអំណាចបុណ្យ ត្រៃគុណនោះណា
ឧត្តមអស្ចារ្យ ថ្លៃថ្លាពេកណាស់ សូមមារសត្រូវ ដែលនៅក្នុងផ្ទះ
កុំមានឱកាស ចូលប្រាស់ទៅហោង ។។

# ព្រហ្មគុណបារមី ១០

ខ្ញុំសូមនមស្សការ លើកហត្ថាចំពោះត្រង់
រតនៈទាំង ៣ អង្គ សូមស្រោចស្រង់ខ្ញុំនេះណា ។
ខ្ញុំសូមរំលឹកទាន ដែលខ្ញុំមានចិត្តជ្រះថ្លា
សាងទុកក្នុងសាសនា តាំងពីក្មេងរៀងដល់ចាស់ ។
ទាំងគុណសីលសីលា ខ្ញុំរក្សាចាំជាក់ច្បាស់
ប្រតិបត្តិកាត់ស្រឡះ អំពើរកម្មវេរាផង ។
ទាំងគុណនៃបព្វជា ខ្ញុំសទ្ធាកាត់ចំណង
អំពើគ្រឿងកាមផង បានថ្វាយខ្លួនក្នុងសាសនា ។
ខ្ញុំសូមរំលឹកដល់ តរកុសលគឺបញ្ញា
ត្រិះរិះក្នុងសិក្ខា ឃើញផ្លូវមគ្គនឹងផ្លូវផល ។
ទាំងគុណសិលវិរិយៈ ខ្ញុំចាំជាក់ដាក់ដិតក់
ព្យាយាមសាងកុសល ឱ្យបានដល់សួគ៌និព្វាន ។
ព្រមទាំងធម៌អំណត់ ខន្តីអត់មិនឱ្យមាន
ទោះពោលពាក្យបំពាន ប្រទូស្តដល់សត្វសង្ខារ ។
ទាំងគុណសីលសច្ចំ ដែលខ្ញុំតាំងក្នុងចិន្តា
មិនហានពោលមុសា ថ្លែងវាចាតែពាក្យពិត ។
ទាំងធម៌អធិដ្ឋាន ដែលខ្ញុំបានត្រេះរិះគិត
តាំងទុកក្នុងគំនិត ឃើញធម៌ពិតក្នុងសាសនា ។

# ព្រះគុណបារមី ១០ គតប់

ព្រមទាំងធម៌ត្រជាក់ រាល់រូបអ្នកគឺមេត្តា
តាំងចិត្តគឺតករុណា ដល់សាកលសត្វទាំងឡាយ ។
គុណសីលឧបេក្ខា ព្រះសាស្តាទ្រង់អធិប្បាយ
រាល់រូបអ្នកទាំងឡាយ ផ្សាយចិត្តចុះធម៌កណ្តាល ។
នេះហៅបារមី ១០ គឺតឱ្យសព្វកុំឱ្យសល់
ចាំទុកដាក់ដំកល់ កាលមរណៈគ្រាន់ទីពឹង ។
គ្រប់រូបអ្នកទាំងឡាយ ប្រុងប្រៀបកាយគឺតជញ្ជីង
ជាផ្លូវត្រូវទីពឹង កុំឱ្យភ្លេចគិតខុសផ្លូវ ។
កុំអាងតែអាចារ្យ ផ្ទឹសោត្តាថាពុទ្ធោ
អង្គុយឡេចច្រងោ ចាំពេលស្លាប់ដូច្នេះឡើយ ។
ត្រូវយើងគឺតជញ្ជីង នឹករំពឹងខ្លួនឯងថា
គ្មានអ្នកដទៃណា ជួយដល់យើងនោះបានឡើយ ។
មានតែគុណព្រះធម៌ វិសេសល្អនេះឯងហើយ
ទានសីលនេះជាត្រើយ ដែលយើងបានកសាងទុក ។
ភាវនាកុំឱ្យភ្លេច លុះដល់ដាច់ខ្យល់ពេលណា
វិញ្ញាណយើងរាល់គ្នា ទៅឋានសួគ៌ និព្វានហោង ។។

មានលក់ដុំ និង លក់រាយ

នូវសៀវភៅគ្រប់មុខគ្រប់ប្រភេទ នៅ

“បណ្ណាគារកំពូលរតន៍” ផ្ទះលេខ 136Eo

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

សូមមិត្ត និង អញ្ជើញយាងមកជ្រើសរើស ។